# វិធីគាំទ្រជនរងគ្រោះ នៃអំពើហិង្សា ទាក់ទងនឹងយេនឌ័រ (GBV) នៅពេល ដែលគ្មានតួអង្គដែល ធ្វើការខាងផ្នែក GBV ក្នុងតំបន់របស់អ្នក

## មគ្គុទ្ទេសក៍ណែនាំ សម្រាប់អ្នកប្រើប្រាស់

**មគ្គុទ្ទេសក៍ណែនាំសម្រាប់អ្នកប្រើប្រាស់នេះ គឺសម្រាប់ប្រើប្រាស់រួមគ្នាជាមួយកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ សម្រាប់គាំទ្រដល់អ្នកអនុវត្តការងារមនុស្សធម៌គ្រប់វិស័យទាំងអស់** ដែលធ្វើប្រតិបត្តិការនៅក្នុងបរិបទដែលគ្មានតួអង្គដែលធ្វើការងារផ្នែក GBV (រួមទាំងច្រកបញ្ជូនករណី GBV ឬ អ្នកឯកទេស/ជនបង្គោល GBV) នៅក្នុងតំបន់របស់អ្នក។




ជនគោលដៅនៃមគ្គុទ្ទេសក៍ណែនាំសម្រាប់អ្នកប្រើប្រាស់នេះ រួមមានប្រធានគ្រប់គ្រងកម្មវិធី អ្នកសម្របសម្រួលបច្ចេកទេស ប្រធានក្រុម ប្រធានផ្នែក និងអ្នកដទៃទៀតដែលមានតួនាទីស្រដៀងគ្នា ក្នុងគ្រប់វិស័យ ដែលទទួលខុសត្រូវគ្រប់គ្រង ត្រួតពិនិត្យ និងកសាងសមត្ថភាពក្រុមការងារនៅសហគមន៍។ ឧទាហរណ៍ ប្រធានគ្រប់គ្រងកម្មវិធី WASH អាចប្រើប្រាស់មគ្គុទ្ទេសក៍ណែនាំសម្រាប់អ្នកប្រើប្រាស់នេះ និង កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ ដើម្បីផ្តល់ព័ត៌មានដោយសង្ខេបជូនដល់អ្នកដែលធ្វើការងារលើកកម្ពស់អនាម័យ អំពីអ្វីដែលត្រូវធ្វើក្នុងករណីដែលជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ប្រាប់រឿងរ៉ាវឱ្យពួកគេដឹងនៅពេលដែលពួកគេកំពុងបំពេញភារកិច្ចប្រចាំថ្ងៃ។

**មគ្គុទ្ទេសក៍ណែនាំសម្រាប់អ្នកប្រើប្រាស់នេះ ត្រូវបានរៀបចំឡើង ដើម្បីផ្តល់សារ និង ការពិចារណាសំខាន់ៗដើម្បី៖**

(១) រៀបចំ និង បង្កើតកម្មវិធី/អន្តរាគមន៍របស់អ្នក និង

(២) ណែនាំក្រុមការងាររបស់អ្នកអំពីរបៀបគាំទ្រជនរងគ្រោះនៃ GBV នៅក្នុងការងារប្រចាំថ្ងៃរបស់ពួកគេ។

យើងសូមលើកទឹកចិត្តឱ្យមានការសម្របសម្រួលជាមួយអ្នកឯកទេសផ្នែក GBV ដើម្បីស្វែងយល់ពីបរិបទ និង ផ្តល់ការណែនាំដោយសង្ខេបអំពីកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ ជូនដល់ក្រុមការងាររបស់អ្នក។ ឯកសារនេះពុំមែនជាមគ្គុទ្ទេសក៍ណែនាំគ្រប់ជ្រុងជ្រោយសម្រាប់អ្នកសម្របសម្រួលឡើយ និង ពុំមែនសម្រាប់ជំនួសគោលគំនិតស្នូលនៃ GBV ឬ ការបណ្តុះបណ្តាលស្តីពី GBV ឡើយ ដោយការបណ្តុះបណ្តាលបែបនេះគប្បីផ្តល់ជូនដល់អ្នកដែលធ្វើការងារមនុស្សធម៌ ដោយតួអង្គដែលធ្វើការងារផ្នែក GBV នៅពេលដែលអាចធ្វើទៅបាន។ បើទោះបីជាកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ ប្រើប្រាស់ក្របខ័ណ្ឌជួយគាំទ្រផ្នែកផ្លូវចិត្តកម្រិតបឋម (PFA) ក៏ដោយ ប៉ុន្តែ គេមិនចាំបាច់តម្រូវឱ្យមានចំណេះដឹង ឬ ការបណ្តុះបណ្តាលពីមុនអំពី PFA ឡើយ។

## មាតិកា

**ទំព័រទី**


**រៀបចំ៖ ការបង្កើតកម្មវិធីប្រកបដោយសុវត្ថិភាព** ........ ៣

គន្លឹះអំពីរបៀបរៀបចំកម្មវិធី និង បុគ្គលិករបស់អ្នក ដើម្បីគាំទ្រដល់ជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ប្រកបដោយសុវត្ថិភាព

**ការផ្តល់ការណែនាំជូនក្រុមការងាររបស់អ្នក** ........ ៥

→ **កន្លះថ្ងៃ**

→ **មួយថ្ងៃពេញ**

សារ និងជំហានសំខាន់ៗ សម្រាប់ណែនាំក្រុមការងាររបស់អ្នកអំពីរបៀបធ្វើការងារជាមួយជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ប្រសិនបើពួកគេប្រាប់អ្នកអំពីរឿងរ៉ាវនេះ

**ឧបសម្ព័ន្ធ១៖ គោលគំនិតគន្លឹះសំខាន់ៗ** ........ ៩

គោលគំនិតសំខាន់ៗដែលត្រូវការឱ្យមាន ដើម្បីផ្តល់ការបណ្តុះបណ្តាលដោយជោគជ័យ។ អាស្រ័យដោយបញ្ហាទាំងអស់នេះគឺជាបញ្ហាស្មុគស្មាញ ដូច្នេះតំណភ្ជាប់មួយចំនួនដើម្បីទទួលបានធនធានបន្ថែមទៀត មានផ្តល់ជូនដើម្បីបំពេញបន្ថែមពីលើអ្វីដែលមានបញ្ចូលនៅក្នុងមគ្គុទ្ទេសក៍ណែនាំនេះ។

**ឧបសម្ព័ន្ធ២៖ ឧបករណ៍បណ្តុះបណ្តាល និង ធនធានបន្ថែមនានា** ........ ១៤

ធនធានបន្ថែមទៀតសម្រាប់រៀបចំផ្តល់ការណែនាំ និង ឯកសារសម្រាប់ចែកជូនអំពីជំនាញទំនាក់ទំនងដែលផ្តោតលើជនរងគ្រោះ។

# រៀបចំ៖
## ការបង្កើតកម្មវិធីប្រកបដោយសុវត្ថិភាព

ការឆ្លើយតបមួយប្រកបដោយសុវត្ថិភាព និងមានភាពគ្រប់គ្រាន់ សម្រាប់ជនរងគ្រោះនៃ GBV ជាដំបូងចាប់ផ្តើមជាមួយនឹងការរៀបចំឱ្យបានគ្រប់ជ្រុងជ្រោយ។ បើទោះបីជាជំហាននេះរមែងតែងត្រូវបានមើលរំលងក៏ដោយ ប៉ុន្តែវាគឺជាជំហានមួយដែលសំខាន់បំផុត។

គោលដៅចម្បងនៃការរៀបចំ គឺដើម្បីស្វែងយល់ថា តើមានជម្រើសអ្វីខ្លះសម្រាប់ជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ នេះគឺជាអ្វីដែលអ្នក ក្នុងនាមជាប្រធានគ្រប់គ្រងកម្មវិធី ប្រធានក្រុម អ្នកដឹកនាំការងារបច្ចេកទេស ឬ អ្នកអនុវត្តការងារដទៃទៀត ដែលអនុវត្តអន្តរាគមន៍មួយ អាចធ្វើបាន៖

### ជំហានទី១៖ អភិវឌ្ឍផែនការមួយ

១. **កំណត់អំពីរបៀប**ដែលអ្នកអាចភ្ជាប់ទំនាក់ទំនងជនរងគ្រោះទៅនឹងសេវាដែលមាន។ សូមមើល ចំនុចទី២។

២. **សុំការបញ្ជាក់**ពីអ្នកឯកទេសផ្នែក GBV ក្នុងប្រទេសរបស់អ្នកអំពីពិធីសារសម្រាប់ចែករំលែកព័ត៌មានអំពីហេតុការណ៍មួយ ដូចជាករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ឬ ហេតុការណ៍ដែលពាក់ព័ន្ធនឹងកុមារ និង ក្មេងជំទង់។ ទាក់ទងទៅសហការីជាតិ ឬ សហការីផ្នែកបច្ចេកទេស នៅក្នុងទីភ្នាក់ងាររបស់អ្នក ដើម្បីសុំការណែនាំបន្ថែម។

៣. **សុំការបញ្ជាក់**អំពីនីតិវិធី និងពិធីសារពាក់ព័ន្ធទៅនឹងការបង្ការទប់ស្កាត់ចំពោះអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ (PSEA)។ ប្រព័ន្ធសម្របសម្រួលការងារមនុស្សធម៌ក្នុងប្រទេសគួរតែអាចផ្តល់ការណែនាំមួយចំនួន។

៤. **កំណត់អំពីរបៀប**ដែលអ្នកអាចកសាង ឬ កែលម្អសមាសធាតុសម្រាប់កាត់បន្ថយហានិភ័យ GBV ទៅក្នុងកម្មវិធី របស់អ្នក។ សូមមើលផ្នែកដែលមានភាពជាក់លាក់ទៅតាមវិស័យការងាររបស់អ្នក នៅក្នុងគោលការណ៍ណែនាំស្តីពី GBV របស់ IASC (http://gbvguidelines.org)។

៥. **កំណត់ថា**តើនរណាគឺជាអ្នកផ្តល់សេវាផ្នែក GBV ចុងក្រោយបំផុត នៅក្នុងតំបន់/ប្រទេសរបស់អ្នក ឬ នៅក្នុងទីភ្នាក់ងាររបស់អ្នក ដើម្បីជាទំនាក់ទំនងសម្រាប់សុំការ**ណែនាំអំពីអ្វីដែលត្រូវធ្វើ** ប្រសិនបើអ្នក ឬ នរណាម្នាក់នៅក្នុងក្រុមការងាររបស់អ្នក ជួបប្រទះសេណារីយ៉ូមួយដែលអ្នកមិនអាចគ្រប់គ្រងបាន ឧទាហរណ៍មួយចំនួនដូចជា៖
   - សេណារីយ៉ូមួយដែលពាក់ព័ន្ធនឹងកុមាររងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ
   - សេណារីយ៉ូមួយដែលពាក់ព័ន្ធនឹងការផ្តល់របាយការណ៍ជាកាតព្វកិច្ច[1]
   - សេណារីយ៉ូមួយដែលជីវិតរបស់ជនរងគ្រោះកំពុងស្ថិតក្នុងគ្រោះថ្នាក់ភ្លាមៗ
   - សេណារីយ៉ូមួយដែលជនរងគ្រោះអាចបង្កគ្រោះថ្នាក់ចំពោះខ្លួនឯង ឬ អ្នកដទៃ។

**ការមិនបង្កគ្រោះថ្នាក់៖**

**មិនត្រូវចែករំលែកព័ត៌មានអំពីជនរងគ្រោះ**

ត្រូវបញ្ជាក់ទៅក្រុមការងាររបស់អ្នកថា ត្រូវការពារអត្តសញ្ញាណ និងសុវត្ថិភាពរបស់ជនរងគ្រោះ ដោយមិនចែករំលែកព័ត៌មានផ្ទាល់ខ្លួន ឬ ព័ត៌មានអត្តសញ្ញាណរបស់ជនរងគ្រោះ ឬ ព័ត៌មានអំពីហេតុការណ៍ដែលបានកើតឡើង ទៅនរណាម្នាក់ដោយគ្មានការអនុញ្ញាតជាក់លាក់ពីជនរងគ្រោះឱ្យចែករំលែកព័ត៌មានរបស់ពួកគេ និង/ឬ បទពិសោធន៍ដែលពួកគេបានជួបប្រទះឡើយ។ ព័ត៌មានផ្ទាល់ខ្លួន ឬ ព័ត៌មានអត្តសញ្ញាណ រួមមានឈ្មោះរបស់ជនរងគ្រោះ លេខចុះបញ្ជីឈ្មោះរបស់ជនភៀស ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋានកន្លែងរស់នៅ អាសយដ្ឋានកន្លែងធ្វើការ ទីតាំងដែលកូនរបស់ពួកគេទៅរៀន ពេលវេលា និងទីកន្លែងជាក់លាក់ដែលហេតុការណ៍បានកើតឡើង។ល។

*1 មានបរិបទមួយចំនួន ដែលមានវិធាននៃការផ្តល់របាយការណ៍ជាកាតព្វកិច្ច ទាក់ទងនឹងប្រភេទករណីជាក់លាក់មួយចំនួន។ សូមសាកសួរជនបង្គោលទទួលបន្ទុកកិច្ចការពាររបស់អ្នក សម្រាប់ព័ត៌មាន និងការណែនាំបន្ថែម។*

## ជំហានទី២៖ ត្រូវដឹងអំពីសេវាដែលមាន

ត្រូវទាក់ទងទៅអ្នកឯកទេសផ្នែក GBV ជានិច្ច ដើម្បីស្វែងយល់អំពីសេវាដែលមាននៅក្នុងតំបន់របស់អ្នក។ បើទោះបីជាអាចគ្មានតួអង្គដែលធ្វើការងារផ្នែក GBV រាប់បញ្ចូលទាំងច្រកបញ្ជូនករណី ឬ ជនបង្គោល GBV នៅក្នុងតំបន់របស់អ្នកក៏ដោយ ប៉ុន្តែ មានសេវាដទៃទៀត ដែលអាចមានសារៈប្រយោជន៍ និង អាចផ្តល់ការគាំទ្រដល់ជនរងគ្រោះ និង សេចក្តីត្រូវការរបស់ពួកគេ។ តួអង្គដែលធ្វើការងារផ្នែកមនុស្សធម៌ ទទួលខុសត្រូវចំពោះតម្រូវការនៃព័ត៌មានប្រកបដោយបច្ចុប្បន្នភាពអំពីសេវា និងកិច្ចគាំទ្រដែលមាននៅក្នុងសហគមន៍ដែលពួកគេធ្វើការងារ។ វាមានសារៈសំខាន់ណាស់ដែលត្រូវដឹងថាតើមានសេវាអ្វីខ្លះ រួមទាំងនៅកម្រិតសហគមន៍ផងដែរ។ ចូរធ្វើការងារជាមួយទីភ្នាក់ងារ និងក្រុមការងាររបស់អ្នក ដើម្បីកំណត់រកជនបង្គោល (ដូចជាតួអង្គដែលផ្តល់កិច្ចគាំទ្រ និង កិច្ចការពារផ្នែកសុខភាពទូទៅ សុខភាពផ្លូវចិត្ត/ចិត្តសង្គម) ដែលអាចផ្តល់ព័ត៌មានអំពីសេវាដែលមាន។

**ធនធាន៖** *សំនួរចាប់ផ្តើមដោយ Ws ចំនួន៣-៤ (តើនរណាធ្វើអ្វី នៅកន្លែងណា និង នៅពេលណា) ប្រធានកម្រង ឬ មេដឹកនាំតាមវិស័យ និង គេហទំព័រ/ទំព័រសម្រាប់ចែករំលែកព័ត៌មាន កិច្ចប្រជុំសម្របសម្រួលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ អង្គការសិទ្ធិស្ត្រី និង អង្គការសង្គមស៊ីវិលក្នុងមូលដ្ឋាន អ្នកផ្តល់សេវាក្នុងមូលដ្ឋាន/អ្នកផ្តល់សេវារបស់រដ្ឋាភិបាល អនុកម្រង ឬ ក្រុមការងារ GBV ក្នុងករណីមានភាពសកម្ម មជ្ឈមណ្ឌលទិន្នន័យរបស់ UNHCR, UN OCHA, humanitarianresponse.info។*

## ជំហានទី៣៖ ពិនិត្យមើលភាពលម្អៀង និង ការសន្និដ្ឋានរបស់អ្នក

ហេតុការណ៍នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រអាចកើតឡើងចំពោះជនគ្រប់រូប ដោយមិនប្រកាន់យេនឌ័រ ទំនោរផ្លូវភេទ អត្តសញ្ញាណយេនឌ័រ ស្ថានភាពអាពាហ៍ពិពាហ៍ ស្ថានភាពពិការភាព អាយុ ជាតិពន្ធ/កុលសម្ព័ន្ធ/ជាតិសាសន៍/សាសនា ជនប្រព្រឹត្តហិង្សា និង ស្ថានភាពដែលអំពើហិង្សាត្រូវបានប្រព្រឹត្ត។ ក្នុងនាមជាអ្នកធ្វើការងារមនុស្សធម៌ ភារកិច្ចរបស់យើងគឺត្រូវគោរព និង ការពារសិទ្ធិរបស់បុគ្គលគ្រប់រូប និង មិនត្រូវធ្វើការសន្និដ្ឋាន ឬ វិនិច្ឆ័យឡើយ។



### សេវាសុខភាព និង ដំណាក់កាលចំហ សម្រាប់ជនរងគ្រោះ

មូលដ្ឋានសុខាភិបាលមួយចំនួន អាចមានសមត្ថភាពផ្តល់ការព្យាបាលដើម្បីបង្ការមេរោគអេដស៍ក្នុងរយៈពេល ៧២ម៉ោង ក្រោយពេលហេតុការណ៍បានកើតឡើង និង បង្ការការមានផ្ទៃពោះមិនតាមប្រាថ្នា ក្នុងរយៈពេល ១២០ ម៉ោងក្រោយពេលហេតុការណ៍បានកើតឡើង។ វាមិនមែនជាតួនាទី ឬ ការទទួលខុសត្រូវរបស់អ្នកក្នុងការប៉ាន់ប្រមាណថាតើមាន ឬ គ្មានសេវាសុខភាពសម្រាប់ជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រឡើយ។ ប៉ុន្តែវាមានសារៈសំខាន់ដែលត្រូវចែករំលែកព័ត៌មានជាមួយជនរងគ្រោះអំពីសេវាសុខភាព ដែលមាននៅក្នុងតំបន់របស់អ្នកជានិច្ច។

វាគឺជាជម្រើសរបស់ជនរងគ្រោះក្នុងការសម្រេចចិត្ត នៅពេលដែលបានផ្តល់នូវរាល់ព័ត៌មានទាំងអស់ជូនដល់ពួកគេ អាស្រ័យ ការស្វែងរកសេវាសុខភាព ផ្តល់នូវអត្ថប្រយោជន៍ផង និងហានិភ័យផង។ អត្ថប្រយោជន៍នៃការស្វែងរកសេវាសុខភាព គឺជាការទទួលបានការព្យាបាលដែលអាចនាំឱ្យទទួលបានលទ្ធផល សុខភាពវិជ្ជមាន។ ហានិភ័យនៃការស្វែងរកការថែទាំ គឺអាចពុំមានសេវា ឬ សេវាអាចមានគុណភាពអន់។ អ្នកផ្តល់សេវាអាចមិនបានប្រុងប្រយ័ត្ន ឬ បង្កឱ្យមានគ្រោះថ្នាក់ ឬ អាចទម្លាយការសម្ងាត់របស់ជនរងគ្រោះ ដែលធ្វើឱ្យពួកគេកាន់តែទទួលរងគ្រោះថ្នាក់បន្ថែមទៀតព្រមទាំងការព្រួយបារម្ភដទៃទៀត។

# ការផ្តល់ការណែនាំជូនក្រុមការងាររបស់អ្នក

## ការរៀបចំកំណត់សម្គាល់ និងឯកសារសម្រាប់ផ្តល់ការណែនាំ៖

១. ចូរអាន និង ស្វែងយល់អំពីកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ និង កំណត់សម្គាល់អំពីសាវតា។ ចូរប្រាស្រ័យទាក់ទងជាមួយអនុកម្រង/ក្រុមការងារ GBV ក្នុងប្រទេសរបស់អ្នក សម្រាប់កិច្ចគាំទ្របច្ចេកទេស និងមគ្គុទ្ទេសក៍ណែនាំ។ ប្រសិនបើគ្មានយន្តការសម្របសម្រួល ឬ ជនបង្គោល GBV នៅក្នុងប្រទេសទេនោះ សូមទាក់ទងទៅកម្រង/វិស័យផ្នែកកិច្ចការពារ។
២. ចូររៀបចំឱ្យមានបញ្ជីរាយនាមសេវាកម្ម និង ជនបង្គោលនៅក្នុងដៃរួចជាស្រេច ដើម្បីចែករំលែកជាមួយក្រុមការងាររបស់អ្នកក្នុងពេលផ្តល់ការណែនាំ។
៣. ពិនិត្យមគ្គុទ្ទេសក៍ណែនាំសម្រាប់អ្នកប្រើប្រាស់នេះឡើងវិញឱ្យបានស៊ីជម្រៅ និង ប្រសិនបើអាច ចូរពិនិត្យមើលឯកសារធនធានបន្ថែម ដូចមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ១ និង ២ ដើម្បីឱ្យយល់ច្បាស់អំពីគោលគំនិតស្នូលរបស់ GBV និង គោលការណ៍ដែលផ្តោតលើជនរងគ្រោះ។
៤. កំណត់ថាតើសិក្ខាកាមរបស់អ្នកដែលនឹងចូលរួមការបណ្តុះបណ្តាលគឺជានរណាខ្លះ។ ក្នុងវគ្គបណ្តុះបណ្តាលមួយលើក គប្បីមានសិក្ខាកាមមិនលើស ២៥នាក់។ ចូរពិចារណាអំពីអត្ថប្រយោជន៍នៃការធ្វើការងារតាមរយៈក្រុមការងារពហុវិស័យ ដើម្បីបង្ហាញអំពីអ្នកផ្តល់សេវាពហុវិស័យ និង/ឬ ដោយឡែក នៅក្នុងទីភ្នាក់ងារមួយ ដើម្បីផ្តោតលើពិធីសារ និងយន្តការផ្តល់របាយការណ៍ និងធនធានជាក់លាក់របស់ទីភ្នាក់ងារនោះ។
៥. ប្រសិនបើមានសុវត្ថិភាព និង មានភាពសមស្រប ចូរប្រមូលសេណារីយ៉ូ ពីបុគ្គលិកសម្រាប់យកមកប្រើប្រាស់ ដោយដកស្រង់ពីបទពិសោធន៍របស់ពួកគេ (ប៉ុន្តែ ត្រូវធ្វើក្នុងលក្ខណៈមួយដែលរក្សាឱ្យបាននូវភាពអនាមិកជាដាច់ខាត និង ធ្វើការផ្លាស់ប្តូរព័ត៌មានលម្អិត ដើម្បីធានាថាគ្មាននរណាអាចស្គាល់ករណីនោះ)។
៦. កែសម្រួលរបៀបវារៈឱ្យស្របតាមលក្ខខណ្ឌតម្រូវនៃបរិបទ និង សិក្ខាកាមរបស់អ្នក ដោយកំណត់យកទម្រង់ដែលល្អបំផុតសម្រាប់ផ្តល់ការបណ្តុះបណ្តាល (វគ្គផ្តល់ការណែនាំចំនួន១ ឬ បំបែកជាច្រើនថ្ងៃ)។
៧. កែសម្រួលលំហាត់ និងឯកសារសម្រាប់ចែកជូន នៅក្នុងឧបសម្ព័ន្ធ២ ដើម្បីធានាថាលំហាត់ និងឯកសារទាំងនោះ មានភាពពាក់ព័ន្ធ និង សមស្របសម្រាប់បរិបទរបស់អ្នក។
៨. ជម្រើសសម្រាប់រយៈពេលពេញមួយថ្ងៃ៖ ចូរទាក់ទងទៅអ្នកឯកទេសផ្នែក GBV នៅក្នុងទីភ្នាក់ងាររបស់អ្នក ឬ ក្នុងចំណោមដៃគូនានា ដើម្បីអភិវឌ្ឍ និង អនុវត្តករណីសិក្សា និង ការសម្តែងតួអង្គ។

# សារគន្លឹះសំខាន់ៗ និង របៀបវារៈសម្រាប់ផ្តល់ការណែនាំ៖

ខាងក្រោមនេះគឺជារបៀបវារៈគំរូសម្រាប់ផ្តល់ការណែនាំ ដែលអ្នកអាចកែសម្រួលទៅតាមបរិបទ និងសេចក្តីត្រូវការរបស់ក្រុមការងារអ្នក។ ពេលវេលាអប្បបរមាដែលត្រូវបានផ្តល់អនុសាសន៍ សម្រាប់ផ្តល់ការណែនាំដល់ក្រុមការងារអំពីកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ គឺត្រូវបណ្តុះបណ្តាលរយៈពេលពេញមួយថ្ងៃ ឬ ៧ម៉ោង ចែកនឹងចំនួនវគ្គក្នុងរយៈពេល ២-៣ សប្តាហ៍ និងកែសម្រួលទៅតាមទម្រង់ជាច្រើនផ្សេងៗគ្នា (ធ្វើបណ្តើររៀនបណ្តើរ ការហាត់ការងារផ្ទាល់។ល។)។ ការធ្វើបែបនេះអនុញ្ញាតឱ្យមានពេលវេលាច្រើនសម្រាប់ពិភាក្សា និងកិច្ចសន្ទនា ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីសារគន្លឹះសំខាន់ៗ ព្រមទាំងគោលការណ៍ណែនាំនានា។ របៀបវារៈរយៈពេលកន្លះថ្ងៃត្រូវបានដាក់បញ្ចូល ព្រមជាមួយនឹងការទទួលស្គាល់អំពី តថភាពជាក់ស្តែងផ្នែកប្រតិបត្តិការនៃភាពអាសន្នធ្ងន់ធ្ងរ។

ប្រសិនបើអ្នកមានពេលច្រើន អ្នកអាចពង្រីកវគ្គដោយប្រើប្រាស់ឯកសារយោង ដូចមានរាយនាមនៅក្នុងឧបសម្ព័ន្ធ២។ គប្បីផ្តោតការយកចិត្តទុកដាក់ដោះស្រាយបញ្ហាឥរិយាបថដែលអាចបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះ និងកែលម្អជំនាញទំនាក់ទំនងដែលផ្តោតលើជនរងគ្រោះ។

## ប្រធានបទ សេចក្តីផ្តើម

កន្លះថ្ងៃ ១៥នាទី | មួយថ្ងៃ ៣០នាទី

### សកម្មភាព

- បង្ហាញអំពីសារគន្លឹះសំខាន់ៗ

### ឧបករណ៍ និងធនធាន

- កំណត់សម្គាល់អំពីសារតា

### សារគន្លឹះ

⇢ ការណែនាំនេះមានគោលដៅផ្តល់នូវព័ត៌មានមូលដ្ឋាន និង ធនធាន អំពីរបៀបជួយដល់នរណាម្នាក់ ប្រសិនបើគេប្រាប់អ្នកថាបានទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ជំនាញដែលយើងនឹងរៀនក្នុងថ្ងៃនេះ អាចយកមកអនុវត្តចំពោះជនទាំងឡាយណាដែលមានសេចក្តីត្រូវការ ប៉ុន្តែយើងនឹងផ្តោតជាក់លាក់លើស្ថានភាពដែលពាក់ព័ន្ធជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

⇢ អ្នកពុំមានតួនាទីក្នុងការស្វែងរកជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រទេ។ ការធ្វើបែបនេះអាចបង្កឱ្យមានគ្រោះថ្នាក់កាន់តែខ្លាំង។ ដោយឡែក យើងនឹងនិយាយអំពីរបៀបដែលយើងអាចធ្វើជាប្រភពធនធានដ៏មានសារៈប្រយោជន៍ ប្រសិនបើមាននរណាម្នាក់មកទាក់ទងយើងដើម្បីសុំជំនួយ។

⇢ តួនាទីរបស់អ្នកគឺត្រូវស្តាប់ដោយមិនធ្វើការវិនិច្ឆ័យ និងផ្តល់ព័ត៌មានដែលត្រឹមត្រូវ និងមានបច្ចុប្បន្នភាព អំពីសេវាដែលមាន ព្រមទាំងអនុញ្ញាតឱ្យជនរងគ្រោះធ្វើការជ្រើសរើសដោយខ្លួនឯង។

⇢ អ្នកពុំមានតួនាទីផ្តល់ប្រឹក្សាយោបល់ ធ្វើកិច្ចសម្ភាស ស្វែងយល់អំពីអ្វីដែលបានកើតឡើង និង ព័ត៌មានលម្អិតនានា ប្រាប់គេអំពីអ្វីដែលត្រូវធ្វើ ឬ ផ្តល់យោបល់ផ្ទាល់ខ្លួននោះទេ។

⇢ ក្នុងនាមជាអ្នកធ្វើការងារផ្នែកមនុស្សធម៌ ភារកិច្ចរបស់យើង គឺត្រូវគោរពនិងការពារសិទ្ធិ និង សេចក្តីត្រូវការរបស់ជនគ្រប់រូបដែលមានសេចក្តីត្រូវការ និង មិនធ្វើការសន្និដ្ឋាន ឬ វិនិច្ឆ័យទេ។

## ប្រធានបទ តើអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) គឺជាអ្វី

កន្លះថ្ងៃ ១៥នាទី | មួយថ្ងៃ ៣០នាទី

### សកម្មភាព

- បង្ហាញអំពីសារគន្លឹះសំខាន់ៗ
- ក្រុមពិភាក្សា និងការបញ្ជាក់អំពីគោលគំនិត

### ឧបករណ៍ និងធនធាន

- ឧបសម្ព័ន្ធ១៖ គោលគំនិតសំខាន់ៗ
- ឧបសម្ព័ន្ធ២៖ ឯកសារសម្រាប់ចែកជូន និង ធនធានបន្ថែម
- ក្រដាសផ្ទាំងធំ និងហ្វឺត

### សារគន្លឹះ

⇢ និយមន័យនៃ GBV៖ ជាពាក្យក្តោបរួមមួយសម្រាប់សកម្មភាពបង្កគ្រោះថ្នាក់ទាំងឡាយណា ដែលប្រព្រឹត្តិផ្ទុយពីឆន្ទៈរបស់មនុស្សម្នាក់ និងដែលផ្អែកលើភាពខុសគ្នាដែលសង្គមបានកំណត់ (ដូចជា យេនឌ័រ) រវាងបុរស និងស្ត្រី។ ពាក្យនេះរាប់បញ្ចូលសកម្មភាពទាំងឡាយណាដែលបង្កគ្រោះថ្នាក់ ឬការឈឺចាប់ផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្ត ការគំរាមកំហែងប្រព្រឹត្តទង្វើបែបនេះ ការបង្ខិតបង្ខំ និងការដកហូតសេរីភាពដទៃទៀត។ សកម្មភាពទាំងនេះអាចកើតឡើងជាសាធារណៈ ឬ នៅកន្លែងឯកជន។

⇢ ប្រភេទ GBV៖ GBV អាចប្រភេទជាអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ឬ ផ្លូវភេទ។ គ្រប់ប្រភេទទាំងអស់នៃ GBV បង្កឱ្យមានផលវិបាករយៈពេលវែងធ្ងន់ធ្ងរ ប៉ុន្តែ គេអាចត្រូវការឱ្យមានការឆ្លើយតបខុសៗគ្នាសម្រាប់អំពើហិង្សាប្រភេទផ្សេងៗគ្នា។

⇢ ផលវិបាកនៃ GBV៖ GBV បង្កឱ្យមានផលវិបាកខាងផ្លូវចិត្ត សុខភាព/ផ្លូវកាយ និង សង្គម។ ក្នុងការឆ្លើយតបចំពោះការប្រាប់ឱ្យដឹងអំពីករណី GBV មួយ យើងត្រូវធានាថាយើងមិនបង្កើតឱ្យមានគ្រោះថ្នាក់បន្ថែមទៀតដោយការធ្វើឱ្យជនរងគ្រោះប្រឈមទៅនឹងការសងសឹកពីជនល្មើស ឬ គ្រួសាររបស់ជនល្មើស ការមាក់ងាយ ឬ ហិង្សាបន្ថែមទៀតពីសហគមន៍ ឬ គ្រួសាររបស់ជនរងគ្រោះ ឬ ដោយការធ្វើឱ្យកាន់តែរងគ្រោះបន្ថែមទៀត ឬ ការបន្ទោសជនរងគ្រោះសម្រាប់ករណីហិង្សាដែលបានកើតឡើង។

## ប្រធានបទ គោលការណ៍ណែនាំ និងការឆ្លើយតបប្រកបដោយសុវត្ថិភាព

កន្លះថ្ងៃ ១៥នាទី | មួយថ្ងៃ ៣០នាទី

### សកម្មភាព

- **បង្ហាញអំពីសារគន្លឹះសំខាន់ៗ**
- **លំហាត់អំពីការយល់ខុស ធៀបនឹងការពិត**

### ឧបករណ៍ និងធនធាន

- **កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ សារគន្លឹះសំខាន់ៗ នៅទំព័រ២ និង៣ និង ១៦ (សម្រាប់កុមារ)**
- **ឧបសម្ព័ន្ធ២៖ ឯកសារសម្រាប់ចែកជូន អំពីឥរិយាបថដែលផ្តោតលើជនរងគ្រោះ**

### សារគន្លឹះ

→ បញ្ជាក់ឡើងវិញអំពីអាណត្តិការងាររបស់អ្នកធ្វើការងារផ្នែកមនុស្សធម៌៖ រាល់អ្នកអនុវត្តការងារផ្នែកមនុស្សធម៌ទាំងអស់ មានអាណត្តិការងារក្នុងការផ្តល់កិច្ចគាំទ្រដោយមិនធ្វើការវិនិច្ឆ័យ និង មិនរើសអើង ចំពោះជនដែលមានសេចក្តីត្រូវការ ដោយមិនប្រកាន់អំពី៖
- យេនឌ័រ
- ទំនោរផ្លូវភេទ
- អត្តសញ្ញាណយេនឌ័រ
- ស្ថានភាពអាពាហ៍ពិពាហ៍
- ពិការភាព
- អាយុ
- ជាតិពន្ធ/កុលសម្ព័ន្ធ/ជាតិសាសន៍/សាសនា
- អ្នកដែលបានប្រព្រឹត្តហិង្សា និង
- ស្ថានភាពដែលអំពើហិង្សាត្រូវបានប្រព្រឹត្ត។

→ តួនាទីរបស់អ្នកគឺត្រូវស្តាប់ដោយមិនធ្វើការវិនិច្ឆ័យ និងផ្តល់ព័ត៌មានដែលត្រឹមត្រូវ និងមានបច្ចុប្បន្នភាព អំពីសេវាដែលមាន ព្រមទាំងអនុញ្ញាតឱ្យជនរងគ្រោះធ្វើការជ្រើសរើសដោយខ្លួនឯង។

→ អ្នកពុំមានតួនាទីផ្តល់ប្រឹក្សាយោបល់ ធ្វើកិច្ចសម្ភាស ស្វែងយល់អំពីអ្វីដែលបានកើតឡើង និងព័ត៌មានលម្អិតនានា ប្រាប់គេអំពីអ្វីដែលត្រូវធ្វើ ឬ ផ្តល់យោបល់ផ្ទាល់ខ្លួននោះទេ។

→ ជនរងគ្រោះគ្រប់រូបមានសេចក្តីត្រូវការផ្សេងៗគ្នា ដូច្នេះគន្លឹះ ដ៏សំខាន់គឺត្រូវស្តាប់ និង ធានាថាពួកគេគឺជាអ្នកដែលធ្វើរាល់ការសម្រេចចិត្តទាំងអស់ដោយយើងជាអ្នកផ្តល់ព័ត៌មាន។

→ អនុវត្តអភិក្រមផ្តោតយកចិត្តទុកដាក់លើជនរងគ្រោះ ដែលមានន័យថាអ្នកអនុវត្ត៖
- **ការគោរព៖** រាល់ចំណាត់ការដែលអ្នកធ្វើ ត្រូវអនុវត្តតាមគោលការណ៍នៃការគោរពចំពោះជម្រើស បំណងប្រាថ្នា សិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ។
- **សុវត្ថិភាព៖** សុវត្ថិភាព និងសន្តិសុខរបស់ជនរងគ្រោះគឺជាអាទិភាពទី១ សម្រាប់គ្រប់តួអង្គអនុវត្តការងារទាំង អស់។
- **ការរក្សាការសម្ងាត់៖** មនុស្សមានសិទ្ធិជ្រើសរើសប្រាប់ ឬ មិនប្រាប់អំពីរឿងរ៉ាវរបស់ពួកគេទៅនរណាម្នាក់។ ការរក្សាការសម្ងាត់ មានន័យថាជាការមិនចែករំលែកព័ត៌មានណាមួយទៅនរណាម្នាក់ដោយគ្មានការអនុញ្ញាតពីជនរងគ្រោះ ទោះនៅពេលណាក៏ដោយ។
- **ការមិនរើសអើង៖** ការផ្តល់ការប្រព្រឹត្តិដោយស្មើភាព និង យុត្តិធម៌ចំពោះជនទាំងឡាយណាដែលត្រូវការជំនួយ។

## ប្រធានបទ រៀបចំ

កន្លះថ្ងៃ ១៥នាទី | មួយថ្ងៃ ៣០នាទី

### សកម្មភាព

- **បទបង្ហាញ**

### ឧបករណ៍ និងធនធាន

- **កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ តារាងលំហូរ ទំព័រ ៤ និង ឯកសារព័ត៌មាន ទំព័រ ៥-៦**

### សារគន្លឹះ

→ ណែនាំឱ្យស្គាល់អំពីកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ។

→ នៅក្នុងតំបន់របស់យើង យើងពុំមានតួអង្គដែលធ្វើការងារផ្នែក GBV ដែលអាចផ្តល់ការថែទាំ និងសេវាឯកទេស ជូនជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រឡើយ។

→ អ្វីដែលយើងមានគឺជាសេវាមួយចំនួនដែលអាចមានប្រយោជន៍ចំពោះសេចក្តីត្រូវការរបស់ជនរងគ្រោះ។

→ បំពេញឯកសារព័ត៌មាន នៅក្នុងកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ។

→ នេះគឺជាព័ត៌មានដែលយើងអាចចែករំលែកជាមួយជនរងគ្រោះបាន និងក្រោយមក វាគឺជាជម្រើសរបស់ជនរងគ្រោះ ក្នុងការសម្រេចចិត្តថាតើពួកគេចង់ទទួលបានសេវាទាំងនេះ ដែរឬទេ (ផ្តល់ព័ត៌មានអំពីសេវា របៀបទទួលបានសេវា និង ជនបង្គោល)។

## ប្រធានបទ មើល និង ស្តាប់

| កន្លះថ្ងៃ | មួយថ្ងៃ |
|---|---|
| ១ម៉ោង | ២.៥ម៉ោង |

### សកម្មភាព

- **បទបង្ហាញ និង ក្រុមពិភាក្សា**

### ឧបករណ៍ និងធនធាន

- **កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ អំពីអ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើ សម្រាប់ មើល ទំព័រ៧ និង ស្តាប់ ទំព័រ៨; ការយល់ឃើញរបស់ជនរងគ្រោះ ទំព័រ១១, ការពណ៌នាអំពីការមើល ទំព័រ១៣, ការពណ៌នាអំពីការស្តាប់ ទំព័រ១៤, ផ្នែកអំពីកុមារ ស្តីពីមើល និងស្តាប់ ទំព័រ១៧ និង១៨។**
- **ឧបសម្ព័ន្ធ២៖ ឯកសារសម្រាប់ចែកជូន អំពីជំនាញទំនាក់ទំនងដែលផ្តោតលើជនរងគ្រោះ**

**មួយថ្ងៃពេញ៖** ការសម្តែងតួអង្គ ( ទាក់ទងទៅអ្នកឯកទេសផ្នែក GBV ដើម្បីអភិវឌ្ឍការសម្តែងតួអង្គដែលមានភាពជាក់លាក់ទៅតាមបរិបទ )

### សារគន្លឹះ

- ⟶ *កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល៖* ចូរពិចារណា សហការសម្របសម្រួលផ្នែកនេះជាមួយអ្នកឯកទេសផ្នែក GBV ណាម្នាក់។
- ⟶ មិនត្រូវមិនអើពើចំពោះនរណាម្នាក់ដែលកំពុងព្យាយាមទាក់ទងដើម្បីសុំការគាំទ្រឡើយ។
- ⟶ សេចក្តីត្រូវការរបស់ជនរងគ្រោះគឺជាអាទិភាពទី១។
- ⟶ រក្សាការសម្ងាត់។ មិនត្រូវធ្វើការចងក្រងឯកសារណាមួយ អំពីជនរងគ្រោះ ឬ ហេតុការណ៍ដែលបានកើតឡើងឡើយ មានន័យថា មិនត្រូវកត់ត្រា ថតរូប កោះហៅគ្នាប្រជុំជាក្រុមជាមួយជនរងគ្រោះ ទាក់ទងទៅប្រព័ន្ធផ្សព្វផ្សាយថតសម្លេងកិច្ចសន្ទនាដោយប្រើទូរស័ព្ទរបស់អ្នក ឬ ឧបករណ៍ដទៃទៀតឡើយ។
- ⟶ អនុញ្ញាតឱ្យជនរងគ្រោះបញ្ចេញអារម្មណ៍របស់ពួកគេ ទោះក្នុងទម្រង់ណាក៏ដោយ ៖ មនុស្សមួយចំនួនមានភាពស្ងៀមស្ងាត់ អ្នកខ្លះទៀតមានអារម្មណ៍ខឹងសម្បារ និងស្រែកខ្លាំងៗ និងអ្នកខ្លះទៀតអាចស្រែកយំ។ល។ ចូរស្តាប់ជនរងគ្រោះ និងសួរថាតើអ្នកអាចជួយពួកគេបានដោយរបៀបណា។ មិនត្រូវសួរសំនួរអំពីអ្វីដែលបានកើតឡើង ឬ ព័ត៌មានលម្អិតអំពីហេតុការណ៍ឡើយ ដោយឡែកគប្បីសង្កត់ធ្ងន់ថាអ្នកមានវត្តមានដើម្បីស្តាប់នូវអ្វីដែលជនរងគ្រោះចង់ចែករំលែក។
- ⟶ ត្រូវដឹងប្រសិនបើអ្នកយល់ឃើញថាអ្នកកំពុងស្ថិតក្នុងស្ថានភាពមួយដែលគ្មានសុវត្ថិភាពសម្រាប់ជនរងគ្រោះ ឬ សម្រាប់ខ្លួនឯង។ អាចមានជនបង្គោលផ្សេងទៀតដែលមានសមត្ថភាពផ្តល់ការគាំទ្របានល្អជានៅក្នុងសេណារីយ៉ូនេះ។
  - *កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល៖* ណែនាំឱ្យស្គាល់អំពីពិធីសារ PSEA និង នីតិវិធីពាក់ព័ន្ធដទៃទៀតនៅក្នុងបរិបទរបស់អ្នក រាប់បញ្ចូលដែនកំណត់នៃការរក្សាការសម្ងាត់ លក្ខខណ្ឌតម្រូវនៃការចែករំលែកព័ត៌មាន/ការផ្តល់របាយការណ៍ និង ការពិចារណាសម្រាប់កុមារ។
- ⟶ **ចងចាំ៖** ប្រសិនបើអ្នកចង់ស្វែងរកកិច្ចគាំទ្រពីប្រធានក្រុម ឬ អ្នកអនុវត្តការងារផ្នែកមនុស្សធម៌ដទៃទៀត ត្រូវសុំការអនុញ្ញាតពីជនរងគ្រោះជាមុនជានិច្ច រួមទាំងការប្រាប់ជនរងគ្រោះឱ្យដឹងថាតើអ្នកចង់និយាយជាមួយនរណា ហេតុអ្វីបានជាអ្នកចង់និយាយជាមួយពួកគេ និង តើអ្នកនឹងចែករំលែកព័ត៌មានអ្វីខ្លះ។ ប្រសិនបើជនរងគ្រោះពុំមានអារម្មណ៍ងាយស្រួល ឬ ប្រកែកភ្លាមៗចំពោះការចែករំលែកព័ត៌មានរបស់ពួកគេ ចូរជួយដល់ពួកគេដោយប្រើប្រាស់ឧបករណ៍នៅក្នុងកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំនេះ។

## ប្រធានបទ ភ្ជាប់ទំនាក់ទំនង

| កន្លះថ្ងៃ | មួយថ្ងៃ |
|---|---|
| ១ម៉ោង | ១.៥ម៉ោង |

### សកម្មភាព

- **បទបង្ហាញ និងក្រុមពិភាក្សា**

### ឧបករណ៍ និងធនធាន

- **កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ អំពីអ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើ ទំព័រ៩-១០, ការពណ៌នាអំពីការភ្ជាប់ទំនាក់ទំនង ទំព័រ ១៥, ផ្នែកអំពីកុមារ ស្តីពីការភ្ជាប់ទំនាក់ទំនង ទំព័រ ១៩។**

### សារគន្លឹះ

- ⟶ កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល៖ ចូរពិចារណា សហការសម្របសម្រួលជាមួយអ្នកឯកទេសផ្នែក GBV ណាម្នាក់។
- ⟶ តួនាទីចម្បងរបស់អ្នកគឺត្រូវផ្តល់ព័ត៌មានអំពីសេវាដទៃទៀត ប្រសិនបើមាន។ ប្រសិនបើមានសេវា ចូរផ្តល់ព័ត៌មានដែលត្រឹមត្រូវជូនជនរងគ្រោះអំពីសេវាដែលមាន ឬ ជម្រើសនានាដើម្បីឱ្យកាន់តែមានផាសុកភាព។
- ⟶ ប្រសិនបើពុំមានសេវា អ្នកចាំបាច់ត្រូវនិយាយដោយស្មោះត្រង់ជាមួយជនរងគ្រោះ ដោយទទួលស្គាល់សេចក្តីក្លាហានរបស់ជនរងគ្រោះដែលបានចែករំលែកបទពិសោធន៍របស់ពួកគេជាមួយអ្នក បង្ហាញឱ្យឃើញថាអ្នកសោកស្តាយដែលអ្នកមិនអាចជួយអ្វីបានលើសពីនេះ និង ផ្តល់ឱ្យជនរងគ្រោះនូវភាពថ្លៃថ្នូរឱ្យបានច្រើនបំផុតទៅតាមដែលអាចធ្វើបាន ក្នុងពេលសន្ទនា។
- ⟶ បញ្ចប់កិច្ចសន្ទនាដោយការយល់ចិត្ត។ សូមចងចាំថាតួនាទីរបស់អ្នកគឺផ្តល់ការគាំទ្រដល់ជនរងគ្រោះចំពោះការសម្រេចចិត្ត និងជម្រើសរបស់ពួកគេ សូម្បីតែជនរងគ្រោះមិនធ្វើការសម្រេចចិត្ត ឬ ធ្វើការជ្រើសរើសអ្វីក៏ដោយ។ មិនត្រូវជួបជាមួយជនរងគ្រោះម្តងហើយម្តងទៀត ផ្តល់ប្រឹក្សាយោបល់ ឬ ប៉ុនប៉ងធ្វើការគ្រប់គ្រងករណីរបស់ជនរងគ្រោះឡើយ។
- ⟶ ក្រោយពេលដែលអ្នកបញ្ចប់កិច្ចសន្ទនា ចូរអនុវត្តតាមពិធីសារជាក់លាក់របស់ទីភ្នាក់ងារ សម្រាប់ការចែករំលែកព័ត៌មានអំពីស្ថានភាពបែបនេះ។ *—កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល៖ ទាមទារឱ្យធ្វើការរៀបចំដើម្បីផ្តល់ព័ត៌មានលម្អិត។*
  - មិនត្រូវចែករំលែកព័ត៌មានអំពីជនរងគ្រោះ ឬ ហេតុការណ៍ដែលបានកើតឡើងជាមួយនរណាម្នាក់ឡើយ។ ចាំបាច់ត្រូវចងចាំថា អ្នកអាចធ្វើអ្វីៗគ្រប់យ៉ាងបានត្រឹមត្រូវ ប៉ុន្តែអ្នកមិនអាចដោះស្រាយបទពិសោធន៍ដែលមនុស្សម្នាក់នេះបានជួបប្រទះ ឬ បំបាត់ការឈឺចាប់របស់គាត់បានឡើយ។ ការស្តាប់បទពិសោធន៍ដែលអ្នកដទៃបានជួបប្រទះ អាចធ្វើឱ្យអ្នកទទួលរងនូវបទពិសោធន៍នៃការឈឺចាប់ និង ការប៉ះទង្គិចផ្លូវចិត្តរបស់ពួកគេ ដែលចំណុចនេះត្រូវបានគេស្គាល់ថាជាការប៉ះទង្គិចផ្លូវចិត្តដោយប្រយោល។ ចូរគិតអំពីរបៀបថែទាំខ្លួនអ្នក នៅពេលដែលអារម្មណ៍ទាំងនេះជ្រៀតចូលក្នុងខ្លួនអ្នក។ ចូរទាក់ទងទៅប្រព័ន្ធ និង បណ្តាញគាំទ្ររបស់អ្នក ដើម្បីទទួលបានការលើកទឹកចិត្ត និង ស្វែងរកកិច្ចគាំទ្រ។ *—កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល៖ ផ្តល់ធនធានអំពីជម្រើសថែទាំសម្រាប់បុគ្គលិក រួមទាំងការផ្តល់លំហរសុវត្ថិភាពជាមួយប្រធានក្រុម ដើម្បីទទួលបានកិច្ចគាំទ្រផ្នែកចិត្តសង្គម។*
- ⟶ ប្រសិនបើអ្នកបារម្ភអំពីសុខុមាលភាពរបស់ជនរងគ្រោះ ឬ ប្រសិនបើជនរងគ្រោះបានទទួលកិច្ចគាំទ្រសមស្រប ចូរធ្វើការតាមដានដោយផ្ទាល់ជាមួយអ្នកផ្តល់សេវា។ មិនត្រូវទាក់ទងទៅជនរងគ្រោះដោយផ្ទាល់ឡើយ។
- ⟶ អាស្រ័យដោយអំពើហិង្សាមានដំណើរការជារង្វង់ អ្នកអាចមើលឃើញមនុស្សម្នាក់នេះម្តងទៀត ឬ ដឹងថាពួកគេទទួលរងហេតុការណ៍ហិង្សាដទៃទៀត។ អ្នកមិនអាចផ្លាស់ប្តូរបទពិសោធន៍របស់ពួកគេបានឡើយ ប៉ុន្តែអ្នកអាចស្តាប់ ជនរងគ្រោះដោយមិនធ្វើការវិនិច្ឆ័យក្នុងអំឡុងពេលនៃហេតុការណ៍នីមួយៗ មិនចំពោះថាអ្នកធ្លាប់ ឬ មិនធ្លាប់និយាយជាមួយពួកគេពីមុនមកឡើយ។

# ឧបសម្ព័ន្ធ១៖ គោលគំនិតគន្លឹះសំខាន់ៗ

## តើអំពើហិង្សាទាក់ទងនឹងយេនឌ័រ គឺជាអ្វី?

**អំពើហិង្សាទាក់ទងនឹងយេនឌ័រ** (GBV) គឺជាពាក្យក្តោបរួមមួយសម្រាប់សកម្មភាពបង្កគ្រោះថ្នាក់ទាំងឡាយណា ដែលប្រព្រឹត្តិផ្ទុយពីឆន្ទៈរបស់មនុស្សម្នាក់ និង ដែលផ្អែកលើភាពខុសគ្នាដែលសង្គមបានកំណត់ (ដូចជា យេនឌ័រ) រវាងបុរស និង ស្ត្រី។ ពាក្យនេះរាប់បញ្ចូលសកម្មភាពទាំងឡាយណាដែលបង្កគ្រោះថ្នាក់ ឬ ការឈឺចាប់ផ្លូវកាយ ផ្លូវភេទ ឬ ផ្លូវចិត្ត ការគំរាមកំហែងការបង្ខិតបង្ខំ និង ការដកហូតសេរីភាពដទៃទៀត។ សកម្មភាពទាំងនេះអាចកើតឡើងជាសាធារណៈ ឬ នៅកន្លែងឯកជន។

**យេនឌ័រ** សំដៅចំពោះភាពខុសគ្នាផ្អែកសង្គម រវាងបុរស និង ស្ត្រីតាមរយៈការរៀនសូត្រ។ បើទោះបីជាបានចាក់ឫសគល់យ៉ាងជ្រៅនៅក្នុងគ្រប់វប្បធម៌ក៏ដោយ ប៉ុន្តែភាពខុសគ្នាផ្អែកសង្គមមានការប្រែប្រួលជាបន្តបន្ទាប់ និងមានភាពខុសគ្នាយ៉ាងទូលំទូលាយ ទាំងនៅក្នុងវប្បធម៌តែមួយ និង រវាងវប្បធម៌ផ្សេងៗគ្នា។ "យេនឌ័រ" កំណត់អំពីតួនាទី ការទទួលខុសត្រូវ ឱកាស បុព្វសិទ្ធ ការរំពឹងទុក និង ភាពមានកម្រិត សម្រាប់បុរស និង ស្ត្រីនៅក្នុងគ្រប់វប្បធម៌ទាំងអស់។

### ឧទាហរណ៍នៃកត្តាដែលរួមចំណែកបង្កឱ្យមាន GBV ក្នុងស្ថានភាពអាសន្ន ឬ ការជម្លៀស៖

- ការគំរាមកំហែងថ្មី/ទម្រង់ថ្មីនៃ GBV ទាក់ទងនឹងជម្លោះ
- កង្វះភាពឯកជន ភាពកកកុញ និង កង្វះលទ្ធភាពទទួលបានសេចក្តីត្រូវការមូលដ្ឋាន
- ការរៀបចំផ្តល់ជំនួយមនុស្សធម៌ បង្កើន ឬ នាំឱ្យមានហានិភ័យ GBV ថ្មី
- ការបែកពីសមាជិកគ្រួសារ ខ្វះឯកសារ ការរើសអើង នៅពេលចុះបញ្ជី
- ការអវត្តមានយន្តការសង្គមដែលផ្តល់កិច្ចការពារ និង អាកប្បកិរិយាដែលកំណត់ចេញនូវនិយាមនានា
- ភាពងាយរងគ្រោះ និងការពឹងផ្អែកមានការកើនឡើង ព្រមទាំងមានការកេងប្រវ័ញ្ច
- ការបង្ហាញឱ្យឃើញនូវសក្តានុពលនៃអំណាចថ្មី ចំពោះតួអង្គដែលធ្វើការងារផ្អែកមនុស្សធម៌។

## តើអ្វីទៅជាបុព្វហេតុបណ្តាលឱ្យមាន GBV?
## តើអ្វីខ្លះជាកត្តារួមចំណែកបង្កឱ្យមាន GBV?

**GBV បណ្តាលពីវិសមភាពយេនឌ័រ និងការរំលោភអំណាច។** នរណាក៏អាច ទទួលរង GBV ដែរ រួមទាំង បុរស កុមារា និង ក្រុមដែលមានទំនោរផ្លូវភេទ និងយេនឌ័រដែលងាយរងគ្រោះ។ ស្របពេលជាមួយគ្នានេះ ស្ត្រី និងកុមារី ទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីអំពើហិង្សាដែលប្រព្រឹត្តដោយបុរសដើម្បីបន្ទាបឋានៈ មិនផ្តល់ភាពអង់អាច ដាក់ទណ្ឌកម្ម ឬត្រួតត្រាលើស្ត្រី និងកុមារី។ យេនឌ័ររបស់ជនល្មើស និង ជនរងគ្រោះ គឺជាចំណុចសំខាន់ ដោយវាមិនត្រឹមតែជាកត្តាកំណត់ ចំពោះការលើកទឹកចិត្តឱ្យប្រព្រឹត្តអំពើហិង្សាប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាកត្តាកំណត់ចំពោះរបៀបដែលសង្គមថ្កោលទោស ឬ ឆ្លើយតប ទៅនឹងអំពើហិង្សាផងដែរ។

**កត្តារួមចំណែក** គឺជាអ្វីម្យ៉ាងដែលធ្វើឱ្យបញ្ហាកាន់តែធ្ងន់ធ្ងរ។ កត្តានានាដែលរួមចំណែកបណ្តាលឱ្យមាន GBV មានភាពខុសៗគ្នាទៅតាមទីកន្លែង ប្រជាជន និងប្រភេទGBV។ មានស្ថានភាពជាច្រើនដែលធ្វើឱ្យGBV កាន់តែធ្ងន់ធ្ងរឡើង ជាពិសេសក្នុងស្ថានភាពអាសន្ន ដូចមានរាយនាមខាងក្រោម។ បើទោះជាដូច្នេះក្តី ឧទាហរណ៍ទាំងនេះគូសបញ្ជាក់អំពីសារៈសំខាន់នៃការដោះស្រាយបញ្ហា GBV តាមរយៈអន្តរាគមន៍ទូលំទូលាយ ដែលកំណត់គោលដៅទៅលើប្រភេទហានិភ័យផ្សេងៗគ្នា។

# ឧបសម្ព័ន្ធ១៖ គោលគំនិតគន្លឹះសំខាន់ៗ (ត)

## តើប្រភេទ GBV មានអ្វីខ្លះ?

### អំពើហិង្សាផ្លូវភេទ

សកម្មភាពផ្លូវភេទទាំងឡាយណាដែលបានសម្រេច ឬ ប៉ុនប៉ងប្រព្រឹត្តផ្ទុយពីឆន្ទៈរបស់មនុស្សម្នាក់ ឬ អ្នកដែលមិនអាចផ្តល់ការអនុញ្ញាតបាន។ ទម្រង់នៃអំពើហិង្សាផ្លូវភេទរួមមាន ការរំលោភសេពសន្ថវៈ (សកម្មភាពផ្លូវភេទដោយបង្ខំ រាប់បញ្ចូលទាំងការប្រព្រឹត្តពីដៃគូស្និទ្ធស្នាល/ប្តី) ការប្រទូស្តកេរ្តិ៍ភេទ ការរំលោភបំពានផ្លូវភេទកុមារ ការកេងប្រវ័ញ្ចផ្លូវភេទដោយជនណាម្នាក់ដែលស្ថិតក្នុងមុខតំណែងមានអំណាច (ដូចជាបុគ្គលិកមនុស្សធម៌) ឬ ដើម្បីជាថ្នូរនឹងប្រាក់ សេវាកម្ម ឬ ទំនិញ។

### អំពើហិង្សាផ្លូវកាយ

អំពើហិង្សាផ្លូវកាយដែលពុំមានលក្ខណៈផ្លូវភេទ។ ទម្រង់នៃអំពើហិង្សាបែបនេះរមែងតែងកើតឡើង នៅក្នុងទំនាក់ទំនងដៃគូស្និទ្ធស្នាល។ វាអាចរួមមានទម្រង់មួយចំនួននៃសកម្មភាពហិង្សា ឬ ការមិនអើពើ ដែលបង្កឱ្យមានការឈឺចាប់ផ្លូវកាយ ឬ របួសស្នាម។ ឧទាហរណ៍រួមមាន៖ ការវាយដំ ការទះកំផ្លៀង ការធ្វើឱ្យថប់ដង្ហើម ការច្រាន ការចាប់ច្របាច់ខ្លាំងៗ ការក្តិច ការខាំ ការបោចសក់ ការធ្វើឱ្យរលាក ការច្របាច់ក ការធ្វើឱ្យមុត ការបាញ់ ឬ ការប្រើអាវុធណាមួយ។

### អំពើហិង្សាផ្លូវអារម្មណ៍ និង ផ្លូវចិត្ត

នេះគឺជាការបង្កឱ្យមានការឈឺចាប់ ឬ របួសផ្លូវចិត្ត។ ចំណុចនេះរាប់បញ្ចូលអំពើហិង្សាដែលប្រព្រឹត្តក្នុងលក្ខណៈមិនពាក់ព័ន្ធនឹងផ្លូវកាយ ដែលជាធម្មតាប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល ឬ ជនដែលស្ថិតក្នុងមុខតំណែងមានអំណាច។ ឧទាហរណ៍ ទម្រង់នៃអំពើហិង្សាផ្លូវអារម្មណ៍ និង ផ្លូវចិត្ត រួមមានការបៀតបៀនដោយពាក្យសម្តី។

### អំពើហិង្សាផ្នែកសង្គម ឬ សេដ្ឋកិច្ច

ចំណុចនេះរាប់បញ្ចូលអំពើហិង្សាដែលប្រព្រឹត្តក្នុងលក្ខណៈអរូបវ័ន្ត ឬ បង្កប់នៅក្នុងច្បាប់ និងគោលនយោបាយដែលបដិសេធន៍ចំពោះស្ត្រី និងកុមារី ព្រមទាំងក្រុមងាយរងគ្រោះដទៃទៀត ការទទួលបានប្រាក់ចំណូល សេវាហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និង ឱកាសនានាក្នុងសង្គម ដើម្បីមានភាពរីកចម្រើន។ ឧទាហរណ៍រួមមាន៖ (១) ការរើសអើង និង/ឬ ការបដិសេធន៍ ចំពោះឱកាស សេវាកម្ម ឬ ធនធាន (២) ការបដិសេធន៍ចំពោះការទទួលបានការអប់រំ ជំនួយផ្នែកសុខភាព ឬ ការងារដែលទទួលបានប្រាក់កម្រៃ និង/ឬ (៣) ការបដិសេធន៍ចំពោះសិទ្ធិលើទ្រព្យសម្បត្តិ។ សមាជិកគ្រួសារ សមាជិកសហគមន៍ សង្គម ស្ថាប័ន និង អង្គការនានាអាចប្រព្រឹត្តអំពើហិង្សាប្រភេទនេះ។

**ការអនុវត្តបែបប្រពៃណីដែលមានដោយគ្រោះថ្នាក់មួយចំនួន** ក៏អាចចាត់ទុកថាជាប្រភេទនៃ GBV ផងដែរ ប្រសិនបើការអនុវត្តទាំងនោះមានចេតនារក្សាឋានៈរបស់ស្ត្រី និងកុមារក្នុងសង្គមឱ្យទាបជាងបុរស។ ក្នុងចំណោមការប្រព្រឹត្តទាំងនេះ ឧទាហរណ៍មួយចំនួនរួមមាន ការកាត់ប្រដាប់ភេទស្ត្រី (FGM) ការបង្ខំរៀបការ និងការរៀបការវ័យក្មេង និង ការសម្លាប់ដើម្បីរក្សាកិត្តិយសគ្រួសារ។

**អំពើហិង្សាពីដៃគូស្និទ្ធស្នាល ដែលត្រូវបានគេស្គាល់ថាជាអំពើហិង្សាក្នុងគ្រួសារផងដែរ** គឺជាទម្រង់មួយនៃការប្រព្រឹត្តរំលោភបំពានក្នុងទំនាក់ទំនងស្និទ្ធស្នាលមួយ រាប់បញ្ចូលទាំងទំនាក់ទំនងអាពាហ៍ពិពាហ៍ ដែលមនុស្សម្នាក់ប្រើប្រាស់ដើម្បីទទួលបានអំណាច ឬ រក្សាអំណាច និងការគ្រប់គ្រងទៅលើមនុស្សម្នាក់ទៀត ។ ទម្រង់នេះរមែងតែងពាក់ព័ន្ធអំពើហិង្សាជាច្រើនប្រភេទផ្សេងៗគ្នា រាប់បញ្ចូលទាំងអំពើហិង្សាផ្លូវចិត្ត ផ្លូវកាយ និងផ្លូវភេទ ផងដែរ។

### កិច្ចការពារពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (PSEA)

កិច្ចការពារពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ គឺជាពាក្យមួយដែលត្រូវបានប្រើប្រាស់ ដើម្បីសំដៅចំពោះជំហាននានាដែលត្រូវបានធ្វើឡើង ដើម្បីការពារជនងាយរងគ្រោះពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ដែលប្រព្រឹត្តដោយតួអង្គដែលធ្វើការងារផ្នែកមនុស្សធម៌ និងបុគ្គលិកពាក់ព័ន្ធ រាប់បញ្ចូលទាំងបុគ្គលិកជំនួយមនុស្សធម៌ អ្នកស្ម័គ្រចិត្ត សន្តិសុខ អ្នកម៉ៅការ បុគ្គលិកបេសកកម្មរបស់អង្គការសហប្រជាជាតិ អ្នករក្សាសន្តិភាព អ្នកផ្គត់ផ្គង់ទំនិញ និងសេវា សម្រាប់គោលបំណងមនុស្សធម៌។ល។

## តើអ្វីផលវិបាកនៃ GBV ចំពោះជនរងគ្រោះ មានអ្វីខ្លះ?

GBV ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពផ្លូវភេទ ផ្លូវកាយ និង ផ្លូវចិត្តរបស់ជនរងគ្រោះភ្លាមៗ ព្រមទាំងរួមចំណែកធ្វើឱ្យមានហានិភ័យកាន់តែខ្ពស់ចំពោះបញ្ហាសុខភាពនៅពេលអនាគត។ អំពើហិង្សាយេនឌ័រ គឺជាបទពិសោធន៍ដែល**គំរាមកំហែងដល់អាយុជីវិត** ក្នុងនោះផលវិបាកមួយចំនួនដែលអាចកើតឡើង រួមមានដូចជា៖

| ផលវិបាកសុខភាពផ្លូវកាយ | ផលវិបាកសុខភាពផ្លូវចិត្ត | ផលវិបាកផ្នែកសង្គម |
|---|---|---|
| របួសផ្លូវកាយ | ការធ្លាក់ទឹកចិត្ត និង ភាពក្រៀមក្រំ | ការបន្ទោសជនរងគ្រោះ |
| ពិការ | ការភ័យខ្លាច និង ការថប់បារម្ភ | ការមាក់ងាយ |
| ជំងឺកាមរោគ រាប់បញ្ចូលទាំងមេរោគអេដស៍ | ការបន្ទោសខ្លួនឯង ការមានអារម្មណ៍ខុសឆ្គង និង ភាពអាម៉ាស់ | ការបដិសេធន៍ និង ការដែលត្រូវគ្រួសារ និង/ឬ សហគមន៍ដាក់ឱ្យនៅដាច់ដោយឡែក |
| ការមានកូនមិនតាមប្រាថ្នា | ការទទួលរងវិបត្តិការប៉ះទង្គិចផ្លូវចិត្តសារឡើងវិញ ការស្រមៃឃើញហេតុការឡើងវិញ | ការរៀបការដោយបង្ខំ |
| ការរំលូតកូនដោយគ្មានសុវត្ថិភាព ការរលូតកូន | ការគេចពីកន្លែង ឬ ស្ថានភាពមួយចំនួន រស់នៅដាច់ដោយឡែកពីគេឯង | សមត្ថភាព/ការរួមចំណែករកប្រាក់មានការធ្លាក់ចុះ |
| ដំបៅស៊ីរូងដោយសាររបួសច្រំដែល | កំហឹង | ភាពក្រីក្រកើនឡើង |
| ការឈឺចាប់រ៉ាំរ៉ៃ | ពិបាកផ្ចង់អារម្មណ៍ ឬ ចងចាំ | ហានិភ័យនៃការរងគ្រោះម្តងទៀត |
| វិបត្តិក្នុងការគេង និងការទទួលទាន | បង្កគ្រោះថ្នាក់ចំពោះខ្លួនឯង | ស្លាប់/ការសម្លាប់ខ្លួនដើម្បីរក្សាកិត្តិយសគ្រួសារ |
| ស្លាប់ រួមទាំងការធ្វើអត្តឃាត | គំនិត/សកម្មភាពចង់ធ្វើអត្តឃាត | |

# ឧបសម្ព័ន្ធ១៖ គោលគំនិតគន្លឹះសំខាន់ៗ (ត)

វាមានសារៈប្រយោជន៍ក្នុងការស្វែងយល់អំពីសក្តានុពលនៃផលវិបាករបស់GBV ដែលអាចប៉ះពាល់ដល់ការប្រព្រឹត្ត និង ជម្រើសរបស់ជនរងគ្រោះ ក្រោយពេលទទួលរងបទពិសោធន៍នៃអំពើហិង្សា។ វាក៏ចាំបាច់ផងដែរ ដែលត្រូវជៀសវាងបង្កគ្រោះថ្នាក់បន្ថែមទៀត ដោយការលើកឡើងអំពីផលវិបាកអវិជ្ជមាននានា ដូចជាការបន្ទោសជនរងគ្រោះសម្រាប់ហេតុការណ៍អំពើហិង្សាដែលនាងបានជួបប្រទះ ឬ តាមរយៈការកាត់បន្ថយប្រតិកម្មរបស់ជនរងគ្រោះមកកម្រិតអប្បបរមា។

ជាចុងក្រោយ ផលវិបាកផ្នែកសង្គមទៅលើជនរងគ្រោះ គឺជាមូលហេតុចម្បងមួយដែលយើងត្រូវធានារក្សាការសម្ងាត់។ ជនរងគ្រោះនឹងមិនស្វែងរកជំនួយឡើយ ប្រសិនបើពួកគេបារម្ភថាមនុស្សគ្រប់គ្នានឹងដឹងរឿងនៅក្នុងគ្រួសារ ឬ សហគមន៍របស់ពួកគេ ដោយសារការភ័យខ្លាចផលវិបាកផ្នែកសង្គម។ កាលណាអ្នកបង្កើតឱ្យមានការជឿទុកចិត្តកាន់តែខ្ពស់ តាមរយៈការសង្កត់ធ្ងន់ និង ការថែរក្សាការសម្ងាត់ ជនរងគ្រោះនឹងទុកចិត្តអ្នក ហើយនឹងមករកអ្នកដើម្បីសុំជំនួយ។

## តើជនរងគ្រោះនៃ GBV ត្រូវការអ្វី?

ដោយសារមានផលវិបាកច្រើននៃGBV ដូចមានរាយនាមខាងលើ ដូច្នេះ ជនរងគ្រោះភាគច្រើនក៏មានសេចក្តីត្រូវការជាច្រើនផ្សេងៗគ្នាដែរ។មិនមែនជនរងគ្រោះគ្រប់រូបសុទ្ធតែមានប្រតិកម្មដូចគ្នាឬមានសេចក្តីត្រូវការដូចគ្នានោះទេ ដូច្នេះរឿងដំបូងគេបង្អស់ដែលត្រូវធ្វើគឺស្តាប់ជនរងគ្រោះ និង សួរជនរងគ្រោះថាតើពួកគេត្រូវការអ្វី ជាជាងសន្និដ្ឋានថាសេចក្តីត្រូវការបន្ទាន់បំផុតមានអ្វីខ្លះ។ ជនរងគ្រោះក៏ត្រូវការឱ្យគេជឿ និងមិនរងការស្តីបន្ទោសចំពោះអំពើហិង្សាដែលបានកើតឡើងទៅលើពួកគេផងដែរ ដើម្បីកសាងឱ្យមានការជឿទុកចិត្ត និងធានាថាពួកគេមានអារម្មណ៍ងាយស្រួលក្នុងការមកសុំជំនួយ។

សុវត្ថិភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះ និងខ្លួនអ្នកផ្ទាល់ គប្បីជាអាទិភាពដំបូងគេបង្អស់ នៅពេលដែលករណី GBV មួយត្រូវបានប្រាប់ឱ្យអ្នកដឹង។ នៅពេលដែលមានសេវាសុខភាពមូលដ្ឋាន ជួនកាលសេវាទាំងនេះអាចជួយកាត់បន្ថយផលវិបាកមួយចំនួននៃ GBV ប៉ុន្តែ សុខភាពផ្លូវចិត្ត និង ផលវិបាកផ្នែកសង្គម រមែងតែងពិបាកដោះស្រាយជាង។ សូមមើលកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំសម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសេវាដែលអាចគាំទ្រដល់ជនរងគ្រោះនៃGBV នៅពេលដែលគ្មានសេវាឯកទេសផ្នែកសុខភាព ចិត្តសង្គម ឬ ច្បាប់ សម្រាប់បញ្ហា GBV។

**សម្រាប់គន្លឹះអំពីរបៀបធានាឱ្យបាននូវសុវត្ថិភាពផ្លូវចិត្ត សូមមើលបញ្ជីរាយនាមអំពីអ្វីដែលត្រូវធ្វើ និង មិនត្រូវធ្វើ នៅក្នុងកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ។**

## តើគោលការណ៍ណែនាំគន្លឹះ ដើម្បីធានាថាយើងមិនបង្កគ្រោះថ្នាក់ចំពោះជនរងគ្រោះនៃ GBV មានអ្វីខ្លះ?

### សិទ្ធិទទួលបាននូវសុវត្ថិភាព៖

សុវត្ថិភាពសំដៅចំពោះសុវត្ថិភាព និងសន្តិសុខផ្លូវកាយពីគ្រោះថ្នាក់ ព្រមទាំងសុវត្ថិភាពផ្លូវចិត្ត និងផ្លូវអារម្មណ៍ សម្រាប់អ្នកដែលមានវិបត្តិតានតឹងខ្ពស់។ ចាំបាច់ត្រូវពិចារណាអំពីសេចក្តីត្រូវការផ្នែកសុវត្ថិភាព និង សន្តិសុខរបស់ជនរងគ្រោះនីមួយៗ សមាជិកគ្រួសាររបស់ពួកគេ និង អ្នកដែលផ្តល់ការថែទាំ និងកិច្ចគាំទ្រ ដោយរាប់បញ្ចូលទាំងខ្លួនអ្នកផ្ទាល់ផងដែរ។ អ្នកដែលប្រាប់ឱ្យដឹងអំពី GBV អាចមានការប្រឈមខ្ពស់ទៅនឹងការទទួលរងអំពើហិង្សាបន្ថែមទៀត ដូចជាអំពើហិង្សាផ្លូវភេទជាអាទិ៍ ពីជនល្មើសផ្ទាល់ អ្នកដែលការពារជនល្មើស

(រាប់បញ្ចូលទាំងគ្រួសាររបស់ពួកគេ មេដឹកនាំ ឬ អាជ្ញាធរក្នុងមូលដ្ឋាន) និង សមាជិកគ្រួសាររបស់ពួកគេផ្ទាល់ ដោយសារគំនិតចង់រក្សាកិត្តិយសគ្រួសារ។

## សិទ្ធិទទួលបានការរក្សាការសម្ងាត់៖

ការរក្សាការសម្ងាត់សំដៅចំពោះសិទ្ធិរបស់ជនណាម្នាក់ ក្នុងការទទួលបានការរក្សាភាពឯកជនអំពីព័ត៌មានណាមួយរបស់ជននោះ លើកលែងតែមានការស្នើសុំច្បាស់លាស់ពីជននោះ។ ការធ្វើបែបនេះជួយលើកកម្ពស់សុវត្ថិភាព ការទុកចិត្ត និងការផ្តល់ភាពអង់អាច។ ការរក្សាការសម្ងាត់មានន័យថាជាការមិនបង្ហាញព័ត៌មានណាមួយ ទោះជានៅពេលណាក៏ដោយ ទៅភាគីណាមួយដោយគ្មានការយល់ព្រមក្រោមមូលដ្ឋាននៃការផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយ ពីជនរងគ្រោះ។ កង្វះការរក្សាការសម្ងាត់ អាចធ្វើឱ្យជនរងគ្រោះ និងអ្នកដទៃទៀត រាប់បញ្ចូលទាំងអ្នកដែលជនរងគ្រោះបានប្រាប់ឱ្យដឹងអំពីករណីហិង្សា មានការប្រឈមចំពោះការរងគ្រោះថ្នាក់បន្ថែមទៀត។

## សិទ្ធិទទួលបានភាពថ្លៃថ្នូរ និង ស្វ័យសម្រេចចិត្ត៖

ជនទាំងឡាយណាដែលមានទំនាក់ទំនងជាមួយជនរងគ្រោះ មានតួនាទីក្នុងការស្តារភាពថ្លៃថ្នូរ និង ស្វ័យសម្រេចចិត្ត ដែល GBV បានធ្វើឱ្យបាត់បង់។ ឧទាហរណ៍ ជនរងគ្រោះមានសិទ្ធិជ្រើសរើស ថាតើពួកគេចង់ប្រាប់ឱ្យនរណាបានដឹងអំពីរឿងរបស់ពួកគេ និង តើពួកគេចង់ទទួលសេវាណាខ្លះ។ ជនរងគ្រោះគឺជាតួអង្គចម្បង ហើយតួនាទីរបស់អ្នកផ្តល់ជំនួយ គឺជាការផ្តល់ព័ត៌មានដែលពួកគេអាចប្រើប្រាស់បាន សម្រាប់ជ្រើសរើសផ្លូវដើម្បីឱ្យពួកគេមានភាពធូរស្បើយឡើងវិញ។ ការខកខានមិនបានគោរពភាពថ្លៃថ្នូរ បំណងប្រាថ្នា និង សិទ្ធិរបស់ជនរងគ្រោះ អាចធ្វើឱ្យអារម្មណ៍អស់សង្ឃឹមនិងភាពអាម៉ាស់របស់ពួកគេមានការកើនឡើង ស្តីបន្ទោសខ្លួនឯង និង បង្កឱ្យរងគ្រោះសារជាថ្មី ព្រមទាំង ទទួលរងគ្រោះថ្នាក់បន្ថែមទៀត។

## សិទ្ធិក្នុងការគ្មានការរើសអើង៖

មនុស្សគ្រប់រូបមានសិទ្ធិទទួលបានជំនួយប្រសើរបំផុត ដោយគ្មានការរើសអើងដោយអយុត្តិធម៌ ក្រោមមូលដ្ឋាននៃយេនឌ័រ អាយុ ពិការភាព ជាតិសាសន៍ ភាសា ជំនឿសាសនាឬនយោបាយ ទំនោរផ្លូវភេទ ឬ វណ្ណៈសង្គម។

### សម្រាប់ព័ត៌មានបន្ថែម និង យល់ដឹងឱ្យកាន់តែស៊ីជម្រៅអំពីគោលគំនិតសំខាន់ៗទាំងនេះ សូមមើល៖

- **គោលការណ៍ណែនាំស្តីពី GBV** (EN, AR, FR, SP): http://gbvguidelines.org/en/home/
- **អ្នកផ្តល់ការឆ្លើយតបផ្នែក GBV**: http://gbvresponders.org/response/core-concepts/
- **ក្រុមការងារ PSEA**: http://www.pseataskforce.org/
- **WHO:** http://apps.who.int/iris/bitstream/10665/44615/1/9789241548205_eng.pdf

# ឧបសម្ព័ន្ធ២៖ ឧបករណ៍បណ្តុះបណ្តាល និង ធនធានបន្ថែមនានា

## ធនធានបន្ថែម៖

យើងបន្តធ្វើបច្ចុប្បន្នភាពបញ្ជីធនធានដែលមានរបស់យើងនៅលើគេហទំព័ររបស់យើងជានិច្ច សម្រាប់**កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ – www.gbvguidelines.org**។ តើអ្នកមានធនធានសម្រាប់ចែករំលែក ឬទេ? សូមអ៊ីមែលមកយើង តាមរយៈអសយដ្ឋាននេះ **gbv.guidelines@gmail.com**។

| វិស័យ/ប្រធានបទ | ធនធាន | តំណភ្ជាប់ |
|---|---|---|
| គោលការណ៍ណែនាំស្តីពី GBV របស់ IASC | សម្ភារៈបណ្តុះបណ្តាលជាភាសាអង់គ្លេស អារ៉ាប់ បារាំង និងអេស្ប៉ាញ | https://gbvguidelines.org/en/training/ |
| ទឹក និងអនាម័យ | កញ្ចប់ឧបករណ៍ស្តីពី អំពើហិង្សាទាក់ទងនឹងយេនឌ័រ និង ទឹកនិងអនាម័យ | http://violence-wash.lboro.ac.uk/ |
| សន្តិសុខស្បៀង | សៀវភៅណែនាំស្តីអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ របស់កម្មវិធីស្បៀងអាហារពិភពលោក (WFP) | https://reliefweb.int/report/world/gen-der-based-violence-manual |
| ជីវភាពរស់នៅ | ឧបករណ៍ CLARA | https://www.womensrefugeecommission.org/empower/resources/1231-clara-tool |
| ជម្រក | កម្រងជម្រក (Shelter cluster GBV Constant Companion) និងគោលការណ៍ណែនាំស្តីពីជម្រក | https://www.sheltercluster.org/gbv |
| សាច់ប្រាក់ | សាច់ប្រាក់ និង ធនធានសម្រាប់កិច្ចការពារពីកម្មវិធីភាពជាដៃគូសម្រាប់ការរៀនសូត្រអំពីសាច់ប្រាក់ (CaLP) | http://www.cashlearning.org/ctp-and-multi-sec-tor-programming/protection |
| លំនៅដ្ឋាន ដីធ្លី និងទ្រព្យសម្បត្តិ (HLP) | ការផ្តល់ លំនៅដ្ឋាន ដីធ្លី និងទ្រព្យសម្បត្តិ (HLP) សម្រាប់ស្ត្រីពី NRC | http://womenshlp.nrc.no/ |
| សុខភាពផ្លូវចិត្ត និងកិច្ចគាំទ្រចិត្តសង្គម | សេចក្តីណែនាំរបស់ WHO ស្តីពីជំនួយសង្គ្រោះ ផ្នែកផ្លូវចិត្តកម្រិតបឋម<br><br>បណ្តាញគាំទ្រសុខភាពផ្លូវចិត្ត និងចិត្តសង្គម | http://www.who.int/mental_health/publications/guide_field_workers/en/<br><br>https://www.mhpss.net/ |

## ឯកសារសម្រាប់ចែកជូន៖

# ជំនាញទំនាក់ទំនងដែលផ្តោតលើជនរងគ្រោះ

### ភាសាកាយវិការ

ភាសាកាយវិកា គឺជាសារដែលយើងបញ្ជូនជាមួយនឹងទឹកមុខរបស់យើង និង ផ្នែកដទៃទៀតនៃរាងកាយរបស់យើង។ ចំណុចនេះ រាប់បញ្ចូលរបៀប/ទីកន្លែងដែលយើងអង្គុយជាមួយអ្នកដទៃ ពេលគឺបរិយាកាសដែលយើងបង្កើតឡើង។ បើជាភាសាអង់គ្លេស យើងប្រើអក្សរកាត់ SOLER ជាវិធីដើម្បីបង្ហាញភាសាកាយវិកាមួយដ៏ល្អសម្រាប់គាំទ្រដល់ជនរងគ្រោះ។

- **ទល់មុខគ្នា៖** មានន័យថា យើងអង្គុយទល់មុខជាមួយជនរងគ្រោះ។
- **គ្មានរបាំង៖** មានន័យថា យើងមិនដាក់វត្ថុអ្វីម៉្យាងនៅចន្លោះរវាងយើង និងជនរងគ្រោះ។ គ្មានតុ គ្មានវត្ថុអ្វីបាំងទាំងអស់។ ចន្លោះរវាងអ្នក និង ជនរងគ្រោះ គឺជាចន្លោះចំហរ/មិនមានការបាំងជិត។
- **បន្ទន់ខ្លួន៖** មានន័យថា យើងត្រូវបន្ទន់ខ្លួនទៅមុខឆ្ពោះទៅរកជនរងគ្រោះ។ ការធ្វើបែបនេះជួយឱ្យជនរងគ្រោះដឹងថាយើងចាប់អារម្មណ៍ចំពោះអ្វីដែលជនរងគ្រោះកំពុងនិយាយ ហើយយើងចង់បន្តនៅស្តាប់ជនរងគ្រោះ។
- **ទំនាក់ទំនងតាមរយៈក្រសៃភ្នែក៖** មានន័យថា យើងរក្សាទំនាក់ទំនងក្រសៃភ្នែកជាមួយជនរងគ្រោះគ្រប់ពេល (លើកលែងតែការធ្វើបែបនេះត្រូវបានចាត់ទុកថាមិនសមស្របខាងផ្នែកវប្បធម៌)។
- **បន្ធូរអារម្មណ៍៖** មានន័យថា យើងអង្គុយក្នុងជំហរបែបបន្ធូរអារម្មណ៍។ វាពុំមែនមានន័យថាយើងអង្គុយលើកៅអីបែបខ្ជិលៗ និង បង្ហាញនូវកាយវិកាមិនយកចិត្តទុកដាក់នោះទេ ប៉ុន្តែ យើងមិនចង់អង្គុយបែបរឹងខ្លួននោះទេ។ យើងចង់ឱ្យមានផាសុកភាព ដើម្បីឱ្យជនរងគ្រោះអាចមានអារម្មណ៍ថាមានផាសុកភាព និង មានការបន្ធូរអារម្មណ៍ដែរ។

### សារតាមរយៈពាក្យសម្តី

សារតាមរយៈពាក្យសម្តី គឺជាអ្វីដែលយើងនិយាយ ឬ ជាខ្លឹមសារនៃកិច្ចសន្ទនា។ ការធ្វើទៅតាមល្បឿនរបស់ជនរងគ្រោះ ការប្រើប្រាស់ភាសាដូចគ្នាទៅនឹងជនរងគ្រោះ និង ការផ្តល់ការពន្យល់សាមញ្ញៗ គឺជាគន្លឹះដើម្បីឱ្យជនរងគ្រោះមានអារម្មណ៍ថាមាន សុវត្ថិភាព និង មានភាពងាយស្រួលក្នុងការចែករំលែកបទពិសោធន៍ដែលពួកគេបានជួបប្រទះ។ វាក៏ជាការល្អផងដែរក្នុងការរៀនរក្សាភាពស្ងៀមស្ងាត់ និងផ្តល់ពេលឱ្យជនរងគ្រោះគិត និង បណ្តោយតាមអារម្មណ៍របស់ជនរងគ្រោះ ប៉ុន្តែការធ្វើបែបនេះអាចមានការពិបាកខ្លាំងសម្រាប់គ្នាយើងមួយចំនួន!

### ជំនាញស្តាប់សកម្ម

- ប្រើសំនួរបើក ដើម្បីស្វែងយល់ថាតើជនរងគ្រោះកំពុងគិត និងមានអារម្មណ៍ដូចម្តេច។
- ថាឡើងវិញ និង សង្ខេប (**"សូមអនុញ្ញាតឱ្យខ្ញុំបញ្ជាក់ឡើងវិញ ដើម្បីឱ្យប្រាកដថាតើខ្ញុំយល់នូវអ្វីដែលអ្នកបានប្រាប់ខ្ញុំកន្លងមកដែរឬទេ"**)។
- ឆ្លុះបញ្ចាំងខ្លឹមសារ និង/ឬ អារម្មណ៍ (**"ស្តាប់ទៅហាក់បីដូចជាអ្នកមានអារម្មណ៍ភ័យខ្លាចខ្លាំងណាស់ នៅពេលដែលគាត់ស្រែកគំហក និងលើកដៃរបស់គាត់បម្រុងវាយអ្នក"**)។ ឆ្លុះបញ្ចាំងថាតើជនរងគ្រោះមានអារម្មណ៍ និង គិតដូចម្តេច ដើម្បីឱ្យជនរងគ្រោះអាចមើលឃើញ ដូចជារូបភាពនោះនៅក្នុងកញ្ចក់។ ជួយឱ្យជនរងគ្រោះមើលឃើញស្ថានភាពរបស់នាង និងជម្រើសរបស់នាងឱ្យបានកាន់តែច្បាស់។ សូមជួយដល់នាងក្នុងការផ្តោតយកចិត្តទុកដាក់។

(នៅមានត)

## ការពិនិត្យផ្ទៀងផ្ទាត់ និង ការធ្វើឱ្យគេយល់ថាជារឿងធម្មតា

- អ្វីដែលល្អបំផុតដែលយើងអាចធ្វើបានគឺជាការស្វែងយល់ និង ទទួលស្គាល់អារម្មណ៍របស់ជនរងគ្រោះ និង ធ្វើឱ្យជនរងគ្រោះយល់ថាអ្វីដែលពួកគេកំពុងមានអារម្មណ៍គឺជារឿងធម្មតា។ ឧទាហរណ៍ ប្រសិនបើជនរងគ្រោះចាប់ផ្ដើមយំ យើងអាចនិយាយថា៖ **អ្នកមានសិទ្ធិក្នុងការមានអារម្មណ៍មិនសប្បាយចិត្ត និងក្រៀមក្រំ។ អ្នកអាចយំនៅទីនេះបាន។ ខ្ញុំនឹងនៅជាមួយអ្នក ហើយយើងអាចនិយាយគ្នាបាននៅពេលដែលអ្នករួចរាល់។**
- ដោយសារតែយើងចង់ឱ្យជនរងគ្រោះ មានអារម្មណ៍ល្អជាងមុន ដូច្នេះសុភាវគតិរបស់យើងអាចជាចង់ប្រាប់ជនរងគ្រោះមិនឱ្យបង្ហាញអារម្មណ៍របស់ពួកគេ ឬ សម្រាលបទពិសោធន៍ដែលពួកគេបានជួបប្រទះ ដូចជា "កុំខ្លាច" "កុំយំ" "វាមិនធ្ងន់ធ្ងរណាស់ណាទេ" "គ្រប់យ៉ាងនឹងមិនអីនោះទេ" ប៉ុន្តែ យើងចង់ឱ្យជនរងគ្រោះដឹងថា ពួកគេកំពុងមាន**ប្រតិកម្មធម្មតា** ចំពោះ**ព្រឹត្តិការណ៍មិនប្រក្រតីមួយ**។ ការធ្វើបែបនេះអាចធ្វើឱ្យយើងមានអារម្មណ៍មិនស្រណុកក្នុងខ្លួន ក្នុងការដែលត្រូវអង្គុយជាមួយនរណាម្នាក់ដែលកំពុងយំ ឬ ខឹង ឬ ធ្លាក់ទឹកចិត្ត ប៉ុន្តែក្នុងនាមជាអ្នកផ្ដល់ជំនួយដ៏ពិតប្រាកដ មានន័យថា យើងអនុញ្ញាតឱ្យពួកគេមានអារម្មណ៍ដែលពួកគេត្រូវការបង្ហាញ។
- ជំនួសឱ្យការប្រាប់ជនរងគ្រោះនូវអ្វីដែលពួកគេមិនត្រូវបង្ហាញអារម្មណ៍ យើងគួរ**ពិនិត្យ**ទៅលើអារម្មណ៍របស់ពួកគេ និង ធ្វើឱ្យគេយល់ថាការមានអារម្មណ៍បែបនោះគឺជារឿង**ធម្មតា**។

ប្រយោគដែលធ្វើឱ្យមានអារម្មណ៍ធូរស្រាល គឺជាអ្វីដែលអ្នកផ្ដល់ជំនួយអាចនិយាយទៅកាន់ជនរងគ្រោះភ្លាមៗ ក្រោយពេលដែលជនរងគ្រោះបានប្រាប់យើងនូវអ្វីដែលបានកើតឡើង និង នៅក្នុងដំណើរការផ្ដល់ជំនួយទាំងមូល ដើម្បីជម្រុញឱ្យជនរងគ្រោះមានការសះស្បើយ និង ធូរស្រាលឡើងវិញ។

- "ខ្ញុំជឿអ្នក។"
- "ខ្ញុំរីករាយដែលអ្នកនិយាយប្រាប់ខ្ញុំ។"
- "ខ្ញុំសោកស្ដាយណាស់ដែលរឿងនេះបានកើតឡើងចំពោះអ្នក។"
- "នេះមិនមែនជាកំហុសរបស់អ្នកទេ។"
- "អ្នកក្លាហានណាស់ដែលនិយាយជាមួយខ្ញុំ។"

## សារតាមរយៈការប្រព្រឹត្ត

សារតាមរយៈការប្រព្រឹត្ត គឺជាអ្វីដែលយើងធ្វើ។ វាមានសារៈសំខាន់ដែលយើងត្រូវផ្ដល់ព័ត៌មាន ប៉ុន្តែយើងមិនត្រូវផ្ដល់ដំបូន្មានទេ។

**ការផ្ដល់ដំបូន្មាន** មានន័យថាជាការប្រាប់នរណាម្នាក់ នូវអ្វីដែលអ្នកគិតថាគេគួរធ្វើ និង តើពួកគេគួរធ្វើដោយរបៀបណា។ នៅក្នុងករណី GBV ការផ្ដល់ដំបូន្មានពុំមានប្រយោជន៍ឡើយ ក្នុងការជួយដល់ជនរងគ្រោះ អាស្រ័យដោយអ្នកមិនដឹង ថាតើអ្នកកំពុងផ្ដល់ដំបូន្មានដែលត្រូវ ដែរឬទេ។ ក្នុងនាមជាអ្នកផ្ដល់ជំនួយ យើងមិនគួរផ្ដល់ដំបូន្មានជូនជនរងគ្រោះជាដាច់ខាត។

**ការផ្ដល់ព័តមាន** មានន័យថាជាការពន្យល់អំពីការពិតជូននរណាម្នាក់ ដើម្បីឱ្យគេអាចធ្វើការសម្រេចចិត្តក្រោមមូលដ្ឋាននៃព័ត៌មានគ្រប់ជ្រុងជ្រោយ អំពីអ្វីដែលត្រូវធ្វើ។ ក្នុងករណី GBV ការផ្ដល់ព័ត៌មាន មានសារៈប្រយោជន៍ អាស្រ័យដោយវាផ្ដល់ភាពអង់អាចដល់ជនរងគ្រោះ ក្នុងការដែលពួកគេអាចគ្រប់គ្រងទៅលើជម្រើសរបស់ពួកគេបាន និង បង្ហាញថាអ្នកគោរពការយល់ឃើញ និង ការវិនិច្ឆ័យរបស់ជនរងគ្រោះ។

# ឯកសារសម្រាប់ចែកជូន៖

# ឥរិយាបថដែលផ្តោតលើជនរងគ្រោះ

ជនរងគ្រោះមិនត្រូវទទួលខុសត្រូវចំពោះអំពើហិង្សាដែលពួកគេបានជួបប្រទះជាដាច់ខាត។ ការប្រើប្រាស់អំពើហិង្សា គឺជាការជ្រើសរើសរបស់ជនល្មើសជានិច្ច។ នេះគឺជាជំនឿមួយដ៏សំខាន់ ដើម្បីធានាឱ្យបាននូវសុវត្ថិភាព និង ការធូរស្រាលឡើងវិញរបស់ជនរងគ្រោះនៃ GBV និង ជៀសវាងបង្កគ្រោះថ្នាក់បន្ថែមទៀត។

យើងទាំងអស់គ្នាសុទ្ធសឹងតែនាំមកនូវឥរិយាបថ និង ជំនឿរបស់យើងមកក្នុងការងារនេះ ហើយឥរិយាបថមួយចំនួនអាចបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះដោយមិនដឹងខ្លួន។ វាមានសារៈសំខាន់ក្នុងការទទួលស្គាល់ និង ចាប់ផ្តើមដេញដោលឥរិយាបថរបស់យើង។

ការបន្ទោសជនរងគ្រោះ គឺជារឿងដែលកើតឡើងទូទៅនៅក្នុងសហគមន៍ជាច្រើន ហើយវាក៏ជាអ្វីដែលយើងត្រូវខិតខំប្រកបដោយភាពប្រតិសកម្មផងដែរ ដើម្បីជៀសវាង និង ប្រឆាំងចំពោះបញ្ហានេះនៅក្នុងការងាររបស់យើងជាមួយជនរងគ្រោះផងដែរ។ ឥរិយាបថដែលផ្តោតលើជនរងគ្រោះ ពាក់ព័ន្ធទៅនឹងការតម្កល់ឧត្តមប្រយោជន៍របស់ជនរងគ្រោះជាអាទិភាព ដោយធានាថារាល់ការងារទាំងអស់មានមូលដ្ឋានផ្អែកលើអ្វីដែលជនរងគ្រោះចង់បាន និងត្រូវការ ជាជាងការយល់ឃើញផ្ទាល់ខ្លួនរបស់យើងចំពោះអ្វីដែលពួកគេចង់បាន និង ត្រូវការ។

| ឥរិយាបថ និង ជំនឿអវិជ្ជមាន | ឥរិយាបថ និង ជំនឿពិតដែលផ្តល់ការគាំទ្រ |
|---|---|
| ប្រសិនបើស្ត្រី ឬ កុមារីដែលមានអាកប្បកិរិយាមិនសមរម្យ ត្រូវបានគេរំលោភ វាគឺជាកំហុសរបស់ពួកគេ។ | អំពើរំលោភសេពសន្ថវៈ គឺជាជម្រើសរបស់ជនល្មើសក្នុងការប្រើប្រាស់អំណាចរបស់ខ្លួនទៅលើមនុស្សម្នាក់ទៀត។ វាមិនមែនជាកំហុសរបស់ជនរងគ្រោះជាដាច់ខាត។ សកម្មភាព GBV រមែងតែងតែជាកំហុសរបស់ជនល្មើសជានិច្ច។ |
| ប្រសិនបើជនរងគ្រោះមិនអាចឆ្លើយសំនួរដែលសួរពួកគេក្នុងពេលសម្ភាសបាន ពួកគេគឺជាអ្នកដែលបង្កឱ្យហេតុការណ៍កើតឡើង។ | ការឆ្លើយតបចំពោះការប៉ះទង្គិចចិត្តសង្គម និងផ្លូវកាយ អាចនាំឱ្យជនរងគ្រោះមានភាពវង្វេងវង្វាន់ និង មិនអាចឆ្លើយសំនួរអំពីហេតុការណ៍ដែលបានកើតឡើង។ |
| ស្ត្រីគឺជាអ្នកធ្វើឱ្យប្តីរបស់ខ្លួនប្រព្រឹត្តអំពើហិង្សា ដោយសារតែអាកប្បកិរិយារបស់នាង។ | អំពើហិង្សាគឺជាជម្រើសរបស់ជនល្មើស និង មិនអាចយកលេសដោះសារដើម្បីប្រើប្រាស់អំពើហិង្សានៅក្នុងទំនាក់ទំនងមួយបានជាដាច់ខាត។ |
| មនុស្សម្នាក់ដែលបង្ខំឱ្យមនុស្សម្នាក់ទៀតរួមភេទ គឺដោយសារតែគាត់មិនអាចគ្រប់គ្រងចំណង់ផ្លូវភេទរបស់គាត់បានប៉ុណ្ណោះ។ | ជនដែលប្រព្រឹត្តអំពើរំលោភសេពសន្ថវៈភាគច្រើន មានការជម្រុញលើកទឹកចិត្តពីអំណាច កំហឹង និង ការគ្រប់គ្រងមិនមែនចំណង់រួមភេទទេ។ បុរសអាចគ្រប់គ្រងចំណង់ផ្លូវភេទរបស់ពួកគេបាន។ អំពើរំលោភសេពសន្ថវៈភាគច្រើនមានការគ្រោងទុកជាមុន ដោយបុរសជាអ្នកគ្រប់គ្រងស្ថានការណ៍នៅពេលដែលគាត់រំលោភ។ |
| អំពើហិង្សាដែលប្រព្រឹត្តពីដៃគូស្និទ្ធស្នាល/អំពើហិង្សាក្នុងគ្រួសារ (IPV) គឺជារឿងក្នុងគ្រួសារ និង គួរដោះស្រាយនៅក្នុងរង្វង់គ្រួសារ។ | IPV គឺជាបញ្ហាកង្វល់ផ្នែកសុវត្ថិភាព និង សុខភាពសម្រាប់សហគមន៍ ហើយវាគឺជាបទល្មើសនៅក្នុងប្រទេសជាច្រើន។ ស្ត្រីរាប់ពាន់នាក់ត្រូវបានសម្លាប់រៀងរាល់ឆ្នាំដោយសារ IPV។ ជនរងគ្រោះនៃ IPV ត្រូវការឱ្យមានកិច្ចគាំទ្រពីសហគមន៍។ |

(នៅមានត)

| ឥរិយាបថ និង ជំនឿអវិជ្ជមាន | ឥរិយាបថ និង ជំនឿពិតដែលផ្ដល់ការគាំទ្រ |
|---|---|
| បុរសភាគច្រើនវាយប្រពន្ធរបស់ពួកគេក្រោយពេលដែលពួកគេផឹកគ្រឿងស្រវឹង ឬ ប្រើគ្រឿងញៀនប៉ុណ្ណោះ។ | គ្រឿងញៀន និង គ្រឿងស្រវឹងអាចជាកត្តារួមចំណែកបង្កឱ្យមាន GBV។ ប៉ុន្តែមានតែការជ្រើសរើសប្រើប្រាស់អំពើហិង្សា អំណាច និង ការគ្រប់គ្រងពីជនល្មើសប៉ុណ្ណោះ ទើបជា មូលហេតុបង្ក នៃ GBV។ មិនមែនបុរសគ្រប់រូបដែលទទួលទានគ្រឿងស្រវឹង ឬ ប្រើប្រាស់គ្រឿងញៀន វាយដំប្រពន្ធរបស់ពួកគេទេ។ បុរសដែលប្រើប្រាស់គ្រឿងស្រវឹង និង គ្រឿងញៀន ធ្វើការសម្រេចចិត្តថាត្រូវវាយនរណា ដែលបង្ហាញឱ្យឃើញថាពួកគេកំពុងជ្រើសរើសគោលដៅប្រព្រឹត្តអំពើហិង្សា។ |
| ជនរងគ្រោះនៃ GBV គួររាយការណ៍អំពីករណីរបស់ពួកគេទៅនគរបាល ឬ អាជ្ញាធរយុត្តិធម៌ដទៃទៀតជានិច្ច។ | ជនរងគ្រោះគប្បីអាចជ្រើសរើសអ្នកដែលពួកគេចង់ប្រាប់ឱ្យដឹងអំពីករណីរបស់ពួកគេ។ |
| បុរសម្នាក់មិនអាចរំលោភប្រពន្ធរបស់ខ្លួនទេ។ | ស្ត្រីគប្បីត្រូវបានអនុញ្ញាតឱ្យប្រាប់ដៃគូរួមភេទរបស់ពួកគេ នៅពេលដែលពួកគេចង់ និង មិនចង់រួមភេទ។ ឥឡូវនេះ ប្រទេសជាច្រើនមានច្បាប់ប្រឆាំងនឹងការរំលោភសេពសន្ថវៈក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍។ ស្ត្រីដែលរៀបការរួច មានសិទ្ធិទទួលបានសុវត្ថិភាពដូចគ្នាទៅនឹងស្ត្រីដែលមិនទាន់រៀបការដែរ។ ស្ត្រីភាគច្រើនដែលរស់នៅជាមួយអំពើហិង្សាដែលប្រព្រឹត្តពីដៃគូស្និទ្ធស្នាល បានទទួលរងនូវទម្រង់មួយចំនួននៃការរំលោភបំពានផ្លូវភេទនៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ពួកគេ។ |
| វាគឺជាការងាររបស់បុគ្គលិកមនុស្សធម៌ក្នុងការកំណត់ថាតើជនរងគ្រោះកំពុងប្រាប់អំពីការពិតដែរឬទេ។ | វាគឺជាការងាររបស់បុគ្គលិកមនុស្សធម៌ ក្នុងការគាំទ្រជនរងគ្រោះ និងជឿជនរងគ្រោះ។ |
| ស្ត្រីត្រូវបានរំលោភ ប្រសិនបើពួកគេស្លៀកពាក់សម្លៀកបំពាក់មិនត្រឹមត្រូវ ឬ ទៅខុសកន្លែង។ | ជនដែលប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ ស្វែងរកជនរងគ្រោះដែលពួកគេគិតថាងាយរងគ្រោះ មិនមែនស្ត្រីដែលស្លៀកពាក់ក្នុងលក្ខណៈជាក់លាក់ណាមួយនោះទេ។ គ្មានបុគ្គលណាម្នាក់ "សក្តិសម" នឹងឱ្យគេរំលោភនោះទេ បើទោះបីជាអាកប្បកិរិយារបស់បុគ្គលនោះមានលក្ខណៈដូចម្ដេចក៏ដោយ។ |
| ស្ត្រីរមែងតែនិយាយកុហកអំពីការដែលត្រូវគេរំលោភ។ | ស្រដៀងគ្នាទៅនឹងការរាយការណ៍ឱ្យដឹងអំពីបទល្មើសកម្រិតធ្ងន់ដទៃទៀតដែរ ការស្រាវជ្រាវកម្រិតសកលបង្ហាញឱ្យដឹងថា ការរាយការណ៍ក្លែងក្លាយអំពីករណីរំលោភសេពសន្ថវៈមានកម្រិតទាបខ្លាំងណាស់។ ករណីនេះគឺដូចគ្នាទៅនឹងបទល្មើសហិង្សាកម្រិតធ្ងន់ដទៃទៀតដែរ។ |
| អំពើរំលោភសេពសន្ថវៈកើតឡើងតែនៅខាងក្រៅ នៅពេលយប់ នៅពេលដែលជនរងគ្រោះនៅតែម្នាក់ឯងប៉ុណ្ណោះ។ | អំពើរំលោភសេពសន្ថវៈ អាច និង ពិតជាកើតឡើងគ្រប់ពេល និង គ្រប់ទីកន្លែង។ អំពើរំលោភសេពសន្ថវៈជាច្រើនកើតឡើងនៅពេលថ្ងៃ ក្នុងផ្ទះរបស់ជនរងគ្រោះ ឧ. កុមារី និង ស្ត្រីពិការ អាចត្រូវបានរំលោភ នៅពេលដែលពួកគេត្រូវបានទុកចោលនៅផ្ទះតែម្នាក់ឯង។ បន្ថែមពីនេះទៀត ជាញឹកញាប់ ស្ត្រី ឬ កុមារី ស្គាល់ជនល្មើស (ឪពុកចុង ពូ។ល។) អំពើរំលោភសេពសន្ថវៈទាំងនេះ រមែងតែងកើតឡើងនៅក្នុងផ្ទះ។ |

(នៅមានត)

| ឥរិយាបថ និង ជំនឿអវិជ្ជមាន | ឥរិយាបថ និង ជំនឿពិតដែលផ្តល់ការគាំទ្រ |
| --- | --- |
| ប្រសិនបើមនុស្សម្នាក់មិន "ប្រឆាំងតបត" នាងមិនមែនត្រូវគេរំលោភនោះទេ។ | អំពើរំលោភសេពសន្ថវៈ អាចមានការគំរាមកំហែងចំពោះអាយុ ជីវិត។ មិនចំពោះថាមនុស្សម្នាក់ធ្វើអ្វីដើម្បីឱ្យរួចផុតពីអំពើប្រទូសកេរ្តិ៍ភេទនោះទេ វាគឺជាសកម្មភាពសមស្រប។ ក្នុងនោះអាចរាប់បញ្ចូលការមិនប្រឆាំងតបត ដោយសារការភ័យខ្លាច។ |
| ប្រសិនបើជនរងគ្រោះមិនបង្ហាញឱ្យឃើញអំពីរបួសរាងកាយពីការរំលោភសេពសន្ថវៈ នាងមិនមែនត្រូវបានគេរំលោភនោះទេ។ | ជនរងគ្រោះអាចមិនបង្ហាញសញ្ញាលើរាងកាយ ដែលបណ្តាលពីអំពើប្រទូសកេរ្តិ៍ភេទ។ |
| ស្មន្តការ (អំពើរំលោភសេពសន្ថវៈ ឬ អំពើរំលោភបំពានផ្លូវភេទ ដោយសមាជិកគ្រួសារ) គឺជាករណីកម្រ។ | ស្មន្តការ គឺជារឿងទូទៅ និង កើតឡើងនៅគ្រប់សហគមន៍ទាំងអស់។ |
| ជាធម្មតា អំពើប្រទូសកេរ្តិ៍ភេទ រមែងតែងកើតឡើងរវាងមនុស្សដែលមិនស្គាល់គ្នា។ | យោងតាមការប៉ាន់ប្រមាណមួយចំនួន ជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈ ជាង ៨០% ស្គាល់អ្នកដែលវាយប្រហារទៅលើពួកគេ។ ជនដែលប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ អាចជាសាច់ញាត មិត្តភក្តិ សហការី មិត្តប្រុស ឬ អ្នកស្គាល់គ្នាដទៃទៀត។ |
| អ្នករកស៊ីផ្លូវភេទ មិនអាចត្រូវគេរំលោភនោះទេ។ | អ្នករកស៊ីផ្លូវភេទ កាន់តែមានការប្រឈម និង ជាកម្មវត្ថុនៃអំពើរំលោភសេពសន្ថវៈ ព្រមទាំងទម្រង់ដទៃទៀតនៃអំពើហិង្សា បើធៀបទៅនឹងស្ត្រីដទៃ។ |
| ជនរងគ្រោះមិនគួរគិតច្រើនពេកអំពីអំពើហិង្សាដែលនាងបានជួបប្រទះនោះទេ។ នាងគួរតែ "បំភ្លេចវាចោល"។ | ជនរងគ្រោះដែលមិនត្រូវបានអនុញ្ញាតឱ្យនិយាយអំពីអំពើហិង្សាដែលពួកគេបានជួបប្រទះ កាន់តែមានការពិបាកក្នុងការធូរស្រាលឡើងវិញ។ ជនរងគ្រោះគ្រប់រូបគប្បីត្រូវបានផ្តល់ឱកាសឱ្យនិយាយអំពីអំពើប្រទូសកេរ្តិ៍ភេទនេះជាមួយអ្នកដែលជិតស្និទ្ធជាមួយពួកគេ ប្រសិនបើពួកគេមានបំណងចង់ធ្វើយ៉ាងដូច្នេះ។ |

**សៀវភៅមគ្គុទ្ទេសក៍នេះបានកែសម្រួលឱ្យស្របជាមួយបរិបទកម្ពុជា**

*បកប្រែជាភាសាខ្មែរ និងបោះពុម្ពផ្សាយដោយអង្គការយូនីសេហ្វប្រចាំនៅកម្ពុជា ដោយផ្អែកលើច្បាប់ដើមជាភាសាអង់គ្លេស និងជាធនធានសកលដែលអន្តរស្ថាប័នបានអនុម័ត។*